ក

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

១.ព្រះរាជក្រម

២៤-៥-២០០៧ -ព្រះរាជក្រម នស/រកម/០៥០៧/០១១ ស្ដីពីការប្រកាសឱ្យប្រើ ច្បាប់ស្ដីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ ៤០៤៦

២.ព្រះរាជក្រឹត្យ

១២-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/១៧៦ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **អ៊ុន ជុនឆយ** (EUNJUN CHOI) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅខេត្តកួងវង់ដូ សាធារណរដ្ឋកូរ៉េ ៤០៨០

១៦-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/១៨១ ស្ដីពីការផ្ដល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ផាក វុនយ៉ុង** (PARK WON YONG) ជនជាតិកូរ៉េ សញ្ជាតិ កូរ៉េ កើតនៅសេអ៊ូល សាធារណរដ្ឋកូរ៉េ ៤០៨១

២១-៥-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៥០៧/១៨៥ ស្ដីពីការបន្ថយរយៈពេលរងទោស ឱ្យទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ៤០៨២

II.រដ្ឋសភា

២៩-៥-២០០៧ -សេចក្ដីសំរេចលេខ ០៣៩ រ ស ស្ដីពីរបបប្រាក់សោធននិវត្តន៍ នៃតំណាងរាស្ត្រ ៤០៩១

III.រាជរដ្ឋាភិបាល

អនុក្រឹត្យ

០៤-៦-២០០៧ -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្ដីពីការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ ៤០៩៤

២៩-៥-២០០៧ -អនុក្រឹត្យលេខ ៤១៩ អនក្រ.តត ស្ដីពីការសំរួល និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤១០១

២៩-៥-២០០៧ -អនុក្រឹត្យលេខ ៤២០ អនក្រ.តត ស្ដីពីការកែតម្រូវមាត្រា ១ នៃអនុក្រឹត្យលេខ ៣១៥ អនក្រ.តត ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៦ ស្ដីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤១០៣

២៩-៥-២០០៧ -អនុក្រឹត្យលេខ ៤២១ អនក្រ.តត ស្ដីពីការផ្លាស់ប្ដូរ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៤១០៤

៣០-៥-២០០៧ -អនុក្រឹត្យលេខ ៤២២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៤១០៦

៣០-៥-២០០៧	-អនុក្រឹត្យលេខ ៤២៣ អនក្រ.តត ស្តីពីការតម្លើងថ្នាក់មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្នុងឋានន្តរស័ក្តិវរមន្ត្រី	៤១០៧
៣១-៥-២០០៧	-អនុក្រឹត្យលេខ ៤២៤ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពិសោធន៍សំណង់ និងសាធារណការ	៤១០៨
៣១-៥-២០០៧	-អនុក្រឹត្យលេខ ៤២៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ	៤១១០
០១-៦-២០០៧	-អនុក្រឹត្យលេខ ៤២៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៤១១១
០១-៦-២០០៧	-អនុក្រឹត្យលេខ ៤២៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី	៤១១៤
០១-៦-២០០៧	-អនុក្រឹត្យលេខ ៤២៨ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ	៤១១៥
០១-៦-២០០៧	-អនុក្រឹត្យលេខ ៤២៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ	៤១១៧
០៤-៦-២០០៧	-អនុក្រឹត្យលេខ ៤៣០ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច តែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ	៤១១៨
០៤-៦-២០០៧	-អនុក្រឹត្យលេខ ៤៣១ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំង មុខតំណែងនាយនគរបាលជាតិ	៤១២០

IV-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

៣០-៥-២០០៧	-ប្រកាសលេខ ៤៧៦ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញ បៀរ បង្កើតរោងចក្រ "ផលិតស្រាបៀរ" ដែលមានឈ្មោះថា "ភ្នំពេញ បៀរ"	៤១២១
៣១-៥-២០០៧	-ប្រកាសលេខ ៤៨០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជី-ហ្វម៉ូស បង្កើតរោងចក្រ "ផលិតស្បែកជើង" ដែលមានឈ្មោះថា "ជី-ហ្វម៉ូស"	៤១២៣
៣១-៥-២០០៧	-ប្រកាសលេខ ៤៨១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុនវ៉ូយុន (ខេមបូឌា) ខូ អិលធីឌី បង្កើតរោងចក្រ "ផលិតស្បែកជើង" ដែលមានឈ្មោះថា "វ៉ូយុន (ខេមបូឌា) ខូ អិលធីឌី"	៤១២៥
០១-៦-២០០៧	-ប្រកាសលេខ ៤៨២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉ាន ក្វាន ស៊ូ បង្កើតរោងចក្រ "ផលិតស្បែកជើង" ដែលមានឈ្មោះថា "យ៉ាន ក្វាន ស៊ូ"	៤១២៧
០១-៦-២០០៧	-ប្រកាសលេខ ៤៨៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊្វូហ្គោ អ៊ិនធើណេសិនណល អ៊ិនវេសមេន បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ហ៊្វូហ្គោ អ៊ិនធើណេសិនណល អ៊ិនវេសមេន"	៤១២៩

០១-៦-២០០៧ -ប្រកាសលេខ ៤៨៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អេហ្វ្រី ម៉ាស្ទ័រ ខូ . អិលធីឌី បង្កើតរោងចក្រ " ផលិតចំណីសត្វ " ដែលមានឈ្មោះថា " អេហ្វ្រី ម៉ាស្ទ័រ ខូ អិលធីឌី " ៤១៣១

០១-៦-២០០៧ -ប្រកាសលេខ ៤៨៥ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ីងហ្គាពួរ កាតុង (ខេមបូឌា) បង្កើតរោងចក្រ " ផលិតកេសកាតុង " ដែលមានឈ្មោះថា " ស៊ីងហ្គាពួរ កាតុង (ខេមបូឌា) " ៤១៣៣

២_ លិខិតការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៤២ ពណ.នតក ស្តីពីការអនុញ្ញាតជាគោលការណ៍អោយបង្កើត ការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន " **ហូលស៊ីម គ្រុប សឺបផត អិលធីឌី** " ប្រចាំរាជធានីភ្នំពេញ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនៅប្រទេសស្វីស ៤០៣៥

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៤៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម អេ អេស ខមភេនី លីមីធីត** ៤១៣៦

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី អ៊ី ស៊ី** ៤១៣៨

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៤៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខូអបភើរេសិន អ៊ិនធើណេសិនណល ឌីវេឡុបមេន (ស៊ី អាយ ឌី)** ៤១៤០

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូនៀន ខបភើរេសិន លីមីធីត** ៤១៤២

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វីស ខបភើរេសិន** ៤១៤៤

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម ធី អ & ជី** ៤១៤៦

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ ស៊ី ស៊ី អ៊ីមផត អិចផត** ៤១៤៨

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈូ ចាង ខូ អិលធីឌី** ៤១៥០

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆូរនស្សន៍ ខ្មែរកាប អង្គរ (អេ ខេ ស៊ី ធី វី)** ៤១៥២

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ អាយ ស៊ី អេ ខូ អិលធីឌី** ៤១៥៤

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីហ្សូ លីង ភីធីអ៊ី អិលធីឌី** ៤១៥៦

២៦-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វ្រីន ឆ្លីស លីមីធីត** ៤១៥៨

២៩-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាយអូវេន ហ្វាម៉ា ស៊្យូធីខល អ៊ីន** ៤១៦០

២៩-០១-២០០៧ -លិខិតបញ្ជាក់លេខ ០៤៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេនសេន គ្រុប អង្គរ លីមីធីត** ៤១៦២

ព្រះរាជក្រម

នស/រកម/០៥០៧/០១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៦ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៣ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.–

ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៤/០០៥ ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ។ ការអនុវត្តនេះលេចចេញជាលទ្ធផលដូចមានចែងក្នុងតារាងសរុបខាងក្រោមនេះ :

ឯកតា:លានរៀល

កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៤	ការអនុវត្តន៍ថវិកា ឆ្នាំ ២០០៤
សរុបចំណូល = (I.១ + II.១)	៣.០១១.០០០	៣.០៩៨.៦៧៦
សរុបចំណាយ = (I.២ + II.២)	៣.០១១.០០០	៣.០០៦.២២១
អតិរេកនៃគណនេយ្យចំណូល/ចំណាយ	-	(+) ៩២.៤៥៥
I. កិច្ចប្រតិបត្តិការចំណូល-ចំណាយថវិកា ដែលបានអនុវត្តតាមរយៈរតនាគារជាតិ		
I.១.ចំណូលថវិកា	២.៣១១.០០០	២.១៧១.២៤០
• ចំណូលចរន្ត	២.១០១.០០០	២.១០៧.២៨៣
• ចំណូលមូលធនក្នុងប្រទេស	២៥.០០០	១៩.៤៥៤
• ចំណូលជាមូលធនក្រៅប្រទេស	១៨៥.០០០	៤៤.៥០៣
I.២.ចំណាយថវិកា	២.៣១១.០០០	២.០៧៨.៧៨៥
• ចំណាយចរន្ត	១.៨៩១.០០០	១.៧៤៦.២៦២
• ចំណាយជាមូលធន	៤២០.០០០	៣៣២.៥២៣
II. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលបានអនុវត្តក្រៅរតនាគារជាតិ[(១)]		
II.១.ធនធានជាមូលធនសំរាប់គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	៧០០.០០០	៩២៧.៤៣៦
II.២.ចំណាយជាមូលធនដោយធនធាន សំរាប់ - គំរោងដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	៧០០.០០០	៩២៧.៤៣៦

(១) គំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានលើកឡើងនេះគ្រាន់តែជាការកត់សម្គាល់ប៉ុណ្ណោះ គឺព្រោះកិច្ចប្រតិបត្តិការដែលបានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេសមិនឆ្លងកាត់រតនាគារជាតិ និង មិនបានចុះកិច្ចបញ្ជីការគណនេយ្យនៅក្នុងពេលអនុវត្ត កិច្ចប្រតិបត្តិការនេះគឺជាលទ្ធផលដែលបានមកពីការផ្ទៀងផ្ទាត់ជាមួយអ្នកគ្រប់គ្រងគំរោង ។

មាត្រា ២.-

ចំណូលថវិកាដែលបានអនុវត្តតាមរយៈរតនាគារជាតិ និង ក្រៅរតនាគារជាតិ ត្រូវបានលំអិតតាមមាតិកាថវិកា នៅក្នុងតារាង “ក” ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយថវិកា ដែលបានអនុវត្តតាមរយៈរតនាគារជាតិក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៤ ត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល និង តាមជំពូក នៅក្នុងតារាង “ខ” ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

លទ្ធផលដែលសំរេចបានស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស ផ្ទាល់ក្នុងរយៈពេលគ្រប់គ្រងឆ្នាំ ២០០៤ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកាដូច មាននៅក្នុងភាគទី II នៃតារាង“ក” និងចំពោះចំណាយត្រូវបានលំអិតនៅក្នុងតារាង“ខ២” ដូចមានជូនភ្ជាប់ជាមួយច្បាប់នេះ ។

ជំពូកទី ២

បទប្បញ្ញត្តិ

ស្តីពីកិច្ចប្រតិបត្តិការចំណូលចំណាយថវិកាដែលបាន អនុវត្តន៍តាមរយៈរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

មាត្រា ៣.-

ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និង ផលទុន ព្រមទាំងការសំរេចបាននូវអំណោយមូលនិធិបរិភាគ និង ធនធាន ដែលបានមកពីការខ្ចី ដែលមានចែងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៤ មានចំនួនទឹកប្រាក់សរុប........................២.៣១១.០០០ លានរៀល

ត្រូវបានអនុវត្តជាក់ស្តែងមានចំនួនទឹកប្រាក់..........២.១៧១.២៤០ លានរៀល

ដូច្នេះមានចំណូលទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន......(-)១៣៩.៧៦០ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ :

ចំណូលចរន្ត ៖

-គំរោង...................................២.១០១.០០០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន...................២.១០៧.២៨៣ លានរៀល

-ខ្ពស់ជាងគំរោងចំនួន.......................(+)៦.២៨៣ លានរៀល

ចំណូលជាមូលធនក្នុងប្រទេស ៖

-គំរោង.......................................២៥.០០០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន.......................១៩.៤៥៤ លានរៀល

-ទាបជាងគំរោងចំនួន..........................(-)៥.៥៤៦ លានរៀល

ចំណូលជាមូលធនក្រៅប្រទេស (ជំពូក ៣១ និង ៣២) ៖

-គំរោង....................................១៨៥.០០០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន.......................៤៤.៥០៣ លានរៀល

-ទាបជាងគំរោងចំនួន.......................(-)១៤០.៤៩៧ លានរៀល

មាត្រា ៤.-

ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលមានចែងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ មានចំនួនទឹកប្រាក់សរុប...............២.៣១១.០០០ លានរៀល

ត្រូវបានអនុវត្តជាក់ស្តែងមានចំនួនទឹកប្រាក់..........២.០៧៨.៧៨៥ លានរៀល

ដូច្នេះមានចំណាយជាក់ស្តែងទាបជាងច្បាប់ហិរញ្ញវត្ថុចំនួន..(-)២៣២.២១៥ លានរៀល

ដែលជាលទ្ធផលនៃការវិវត្តន៍ដូចតទៅ ៖

ចំណាយចរន្ត ៖

-គំរោង..................................១.៨៩១.០០០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន..................១.៧៤៦.២៦២ លានរៀល

-ទាបជាងគំរោងចំនួន.......................(-)១៤៤.៧៣៨ លានរៀល

ចំណាយជាមូលធននៃវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស ៖

-គំរោង....................................៣២៥.០០០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន.....................២៨៦.៤៧៨ លានរៀល

-ទាបជាងគំរោងចំនួន........................(-)២៨.៥២២ លានរៀល

ចំណាយជាមូលធននៃការវិលសំបិណុល :

-គំរោង..៩៥.០០០ លានរៀល

-អនុវត្តជាក់ស្តែងបានចំនួន........................៣៦.០៤៥ លានរៀល

-ទាបជាងគំរោងចំនួន........................(-)៥៨.៩៥៥ លានរៀល

មាត្រា ៥.-

ការអនុវត្តកិច្ចប្រតិបត្តិការចំណូល និង ចំណាយតាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដែលបានអនុវត្តជាក់ស្តែងតាមរយៈរតនាគារជាតិ ដូចមានចែងក្នុងមាត្រា ៣ និង មាត្រា ៤ នៃច្បាប់នេះបានបង្ហាញជាលទ្ធផលនូវអតិរេកគណនេយ្យនៃចំណូល និង ចំណាយដូចតទៅ :

-ចំណូលថវិកាដែលបានអនុវត្តជាក់ស្តែងតាមរយៈរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ មានចំនួន..........................២.១៧១.២៤០ លានរៀល

-ចំណាយថវិកាដែលបានអនុវត្តជាក់ស្តែងតាមរយៈរតនាគារជាតិសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ មានចំនួន..........................២.០៧៨.៧៨៥ លានរៀល

-អតិរេកពិតនៃគណនេយ្យចំណូល និង ចំណាយ...(+)៩២.៤៥៥ លានរៀល

អតិរេកគណនេយ្យនេះ គឺជាលទ្ធផលនៃ :

-អតិរេកនៃចំណូលចរន្ត និង ចំណាយចរន្ត...(+)៣៦១.០២១ លានរៀល

-និងឱនភាពនៃចំណូលមូលធននិងចំណាយមូលធន..(-)២៦៨.៥៦៦ លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៅក្នុងមាត្រា ៥៧ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ អតិរេកគណនេយ្យនៃចំណូល និង ចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ មានចំនួនទឹកប្រាក់ (+)៩២.៤៥៥ លានរៀល ត្រូវបានកត់ត្រានៅក្នុងគណនីលទ្ធផល ដែលបានបើកនៅក្នុងលេខានៃរតនាគារជាតិ ។

ROYAUME DU CAMBODGE

ជំពូកទី ៣

បទប្បញ្ញត្តិ

ស្តីពីវិនិយោគសាធារណៈ

ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់

ដែលបានអនុវត្តក្រៅរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

មាត្រា ៦.–

វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលបានអនុវត្តនៅក្រៅរតនាគារជាតិ និង ដែលបានគ្រោងទុកសរុបចំណូលស្មើនឹងសរុបចំណាយសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ មានចំនួនទឹកប្រាក់..........................៧០០.០០០ លានរៀល

ត្រូវបានអនុវត្តជាក់ស្តែងមានចំនួនទឹកប្រាក់............៩២៧.៤៣៦ លានរៀល

ដូច្នេះមានចំនួនខ្ពស់ជាងគំរោង....................(+)២២៧.៤៣៦ លានរៀល

ជំពូកទី ៤

បទប្បញ្ញត្តិស្តីពីតុល្យភាព

ហិរញ្ញវត្ថុសាធារណៈសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

មាត្រា ៧.–

តុល្យភាពហិរញ្ញវត្ថុ ដែលបានសំរេចបានជាស្ថាពរសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ បានឆ្លុះបញ្ចាំងនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចខាងក្រោម ៖

ឯកតា:លានរៀល

តារាងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ	ចំនួនទឹកប្រាក់	ចំនួនលើស(+) /ឱនភាព(-)
I- ចំណូលក្នុងប្រទេស	២.១២៦.៧៣៧	
I.១. ចំណូលចរន្ត	២.១០៧.២៨៣	
I.២. ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម)	១៩.៤៥៤	
II- ចំណាយថវិកា	២.៩៧០.១៧៦	
II.១. ចំណាយចរន្ត	១.៧៤៦.២៦២	
II.២. ចំណាយជាមូលធន (២) ក្នុងនោះ ÷	១.២២៣.៩១៤	
+វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស	២៩៦.៤៧៨	
- ដោយមូលនិធិថវិកា	២២៩.៤៩៤	
- គំរោងវិនិយោគ (សាងសង់ និង ទិញសំភារៈ)	១៤៤.៣៧១	
• បដិភាគរួមចំណែកជាមួយវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់	៨៥.១២៣	
- ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ	៦៦.៩៨៤	
+វិនិយោគសាធារណៈដោយប្រើហិរញ្ញប្បទានពីក្រៅប្រទេសផ្ទាល់(ជំនួយគំរោងការ)	៩២៧.៤៣៦	
ក.អតិរេកថវិកាចរន្ត (តាមនិយមន័យសន្សាផ្តល់)(I.១ − II.១)		(+)៣៦១.០២១
ខ.ឱនភាពនៃថវិកាទូទៅ (តាមនិយមន័យសន្សាផ្តល់) (I – II)		(-)៨៤៣.៤៣៩
III- កំណែតំរូវ		(-)២១.១១៥ (៣)
អតិរេកនៃថវិកាចរន្ត(តាមនិយមន័យបេឡា)= (ក + III)		(+)៣៣៩.៩០៦
ឱនភាពនៃថវិកាទូទៅ(តាមនិយមន័យបេឡា) = (ខ + III)		(-)៨៦៤.៥៥៤
IV- ហិរញ្ញប្បទាននៃឱនភាព		(+)៨៦៤.៥៥៤
១. ហិរញ្ញប្បទានក្រៅប្រទេស		(+)៩២៥.០៨៣
• ជំនួយទ្រទ្រង់ថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ		(+)៤៤.៥០៣
• ជំនួយគំរោងការ		(+)៩០៥.៣៤៩
• ការវិលសងបំណុលបរទេស		(-)២៤.៧៦៩
២. ហិរញ្ញប្បទានក្នុងប្រទេស		(-)១០៩.៩៩៦
• ហិរញ្ញប្បទានធនាគារ		(+)២៤.១៤០
-ប្រាក់បញ្ញើរដ្ឋាភិបាល		(+)២៦.០២២
-បំណុលរដ្ឋាភិបាល		(-)១.៨៨៣
ក្នុងនោះ -បុរេប្រទានពីធនាគារជាតិ		(-)១.៤៨៥
-ការវិលសងកម្ចីពាណិជ្ជកម្ម		(-)១.៩៤៥
-លំអៀង (អត្រាប្តូរប្រាក់)		(+)១.៥៤៧
• ប្រាក់បញ្ញើផ្សេងៗទៀតរបស់រដ្ឋាភិបាល		(-)៦.៣១៩
• វិស័យឯកជន		(-)១២៥.៨០៣
-ប្រាក់រំលោះកម្ចីផ្ទៃក្នុង		(-)៧.៨៤៦
-គណនីបុគ្គល/បញ្ញើធានា		(-)១១៧.៩៥៧
• លំអៀងគណនីរវាងធនាគារជាតិ និង ក្រសួងហិរញ្ញវត្ថុ		(-)២.០១៤
៣. និទ្ទេសប្រតិបត្តិការកំពុងដំណើរការ		(+)៤៩.៤៦៧

(២) មិនទាន់គិតបញ្ចូលការប្រាក់ចំណាយ ៣៦.០៤៥ លានរៀល (២៤.៧៦៩ + ១.៤៨៥ + ១.៩៤៥ + ៧.៨៤៦) ។

(៣) គិតបញ្ចូលសុទ្ធនៃអាណត្តិបើកប្រាក់ ដែលមានសល់មិនទាន់បានបើកផ្តល់នៅរតនាគារជាតិ និង បុរេប្រទានត្រូវធ្វើនិយ័តភាវូបនីយកម្ម ។

ជំពូកទី ៥

បទប្បញ្ញត្តិស្តីពីការទូទាត់
ថវិការបស់ខេត្ត-ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

មាត្រា ៨.-

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ និង មាត្រា ១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៤/០០៥,ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៤ ត្រូវបានយល់ព្រមតាមការអនុវត្តនូវកិច្ចប្រតិបត្តិការចំណូល និងចំណាយថវិការបស់ខេត្ត-ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដែលលេចចេញជាលទ្ធផលដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ :

កិច្ចប្រតិបត្តិការចំណូល និង ចំណាយថវិការបស់ខេត្ត-ក្រុងសំរាប់ការគ្រប់គ្រងឆ្នាំ២០០៤	ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៤	ការអនុវត្តថវិកាខេត្ត-ក្រុងឆ្នាំ ២០០៤	លើស(+) ខ្វះ(-)
សរុបចំណូល	១០១.០០០.០០០.០០០	១២៦.៦៥២.៣៤៤.៨១២	+២៥.៦៥២.៣៤៤.៨១២
សរុបចំណាយ	១០១.០០០.០០០.០០០	១០៩.៧១០.៣៥២.៣៦២	+៨.៧១០.៣៥២.៣៦២
អតិរេកគណនេយ្យនៃចំណូល និង ចំណាយ		១៦.៩៤១.៩៩២.៤៥០	+១៦.៩៤១.៩៩២.៤៥០
កិច្ចប្រតិបត្តិការនៃថវិការបស់ខេត្ត ក្រុង			
I. ចំណូលថវិកា	១០១.០០០.០០០.០០០	១២៦.៦៥២.៣៤៤.៨១២	+២៥.៦៥២.៣៤៤.៨១២
- ចំណូលចរន្ត	១០១.០០០.០០០.០០០	១២៦.៦៥២.៣៤៤.៨១២	+២៥.៦៥២.៣៤៤.៨១២
• ចំណូលសារពើពន្ធ	៥០.០០០.០០០.០០០	៧៥.០៦៤.៨៩៥.៨១១	+២៥.០៦៤.៨៩៥.៨១១
• ចំណូលពុំមែនសារពើពន្ធ	១១.០០០.០០០.០០០	១៤.៥៨៧.៤៤៩.០០១	+៣.៥៨៧.៤៤៩.០០១
• ឧបត្ថម្ភពីថវិកាជាតិ	៤០.០០០.០០០.០០០	៣៧.០០០.០០០.០០០	-៣.០០០.០០០.០០០
- ចំណូលជាមូលធន	០	០	០
• ចំណូលជាមូលធនផ្ទៃក្នុង	០	០	០
• ចំណូលជាមូលធននៃវិនិយោគដោយថវិកាជាតិ (កម្មវិធីសិលា)	០	០	០
II. ចំណាយថវិកា	១០១.០០០.០០០.០០០	១០៩.៧១០.៣៥២.៣៦២	+៨.៧១០.៣៥២.៣៦២
- ចំណាយចរន្ត	១០១.០០០.០០០.០០០	១០៩.៧១០.៣៥២.៣៦២	+៨.៧១០.៣៥២.៣៦២
- ចំណាយជាមូលធន	០	០	០
III. អតិរេកថវិកា	០	១៦.៩៤១.៩៩២.៤៥០	+១៦.៩៤១.៩៩២.៤៥០

មាត្រា ៩.–

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ២២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣, ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ អតិរេកនៃថវិការបស់ខេត្ត-ក្រុង ដែលមានចំនួនទឹកប្រាក់ ១៦.៩៤១.៩៩២.៤៥០ រៀល ត្រូវបានបង់ចូលថវិកាទូទៅរបស់រដ្ឋ ។

ជំពូកទី ៦

បទប្បញ្ញត្តិស្តីពី

និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ

ចំណាយថវិកាបន្ថែមសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤

មាត្រា ១០.–

ដោយអនុលោមតាមបទប្បញ្ញត្តិមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ និងបទប្បញ្ញតិនានានៃវិសោធនកម្មច្បាប់នេះ និង មាត្រា ១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ត្រូវបានអនុម័តយល់ព្រមឱ្យចំណាយថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៤ ដូចខាងក្រោម :

-ចំណាយទូទាត់បុរេប្រទានឆ្នាំ ១៩៩១-២០០០ ចំនួន ៩០០ លានរៀលរបស់រដ្ឋសភាជាតិ ។

-ចំណាយទូទាត់បុរេប្រទានរៀបចំសន្និសិទ្ធ AIFOCOM និងមហាសន្និបាត AIPO ឆ្នាំ ២០០៤ ចំនួន ៥.៣០០ លានរៀល របស់រដ្ឋសភាជាតិ ។

-ចំណាយទូទាត់បុរេប្រទានឆ្នាំ ១៩៩១-២០០០ ចំនួន ៣.២០៩ លានរៀល របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

-ចំណាយទូទាត់បុរេប្រទានឆ្នាំ ១៩៩១-២០០០ ចំនួន ៦៦២ លានរៀលរបស់ក្រសួងមហាផ្ទៃផ្នែករដ្ឋបាលទូទៅ ។

-ចំណាយទូទាត់បុរេប្រទានឆ្នាំ ១៩៩១-២០០០ ចំនួន ១៨១ លានរៀលរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

-ចំណាយទូទាត់បុរេប្រទានឆ្នាំ ១៩៩៩-២០០០ ចំនួន ២៩៩ លានរៀលរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ១១.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១២.-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៧

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៧០៥.២១០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខៈ ២០៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ការគ្រប់គ្រងឆ្នាំ ២០០៤

តារាង "ក"

ចំណូលថវិកាជាតិរបស់រដ្ឋ

ឯកតា: រៀល

ជំពូក	គណនី	អនុគណនី	កម្រិតលម្អិត	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៤	ការអនុវត្តថវិកា ឆ្នាំ ២០០៤	ការអនុវត្ត / ច្បាប់ហិរញ្ញវត្ថុ លើស (+) ខ្វះ (-)	ការអនុវត្ត / ច្បាប់ហិរញ្ញវត្ថុ ភាគរយ
				សរុបចំណូលថវិកាជាតិរបស់រដ្ឋ (I+II)	3.011.000.000.000	3.098.676.372.702	87.676.372.702	102,91%
				I. សរុបចំណូលថវិកាជាតិរបស់រដ្ឋ ក្នុងគនាគារ (ក + ខ)	2.311.000.000.000	2.171.240.372.702	-139.759.627.298	93,95%
				ក្នុងនោះចំណូលក្នុងស្រុក	2.126.000.000.000	2.126.737.520.581	737.520.581	100,03%
				ក. សរុបចំណូលចរន្ត	2.101.000.000.000	2.107.282.905.547	6.282.905.547	100,30%
				ប្រភេទទី១: ពន្ធ និង អាករ	1.470.000.000.000	1.577.490.932.173	107.490.932.173	107,31%
10				ជំពូក១០:ពន្ធលើផលខុនប្រាក់ចំណេញ និងកំរៃខុន	171.700.000.000	158.089.789.426	-13.610.210.574	92,07%
	01			ពន្ធលើប្រាក់បៀវត្ស	28.700.000.000	28.454.954.882	-245.045 118	99,15%
	02			ពន្ធលើប្រាក់ចំណេញរបស់រោងចក្រ និង ពាណិជ្ជកម្ម	131.500.000.000	117.498.193.577	-14,001.806 423	89,35%
		01		សហគ្រាសសាធារណៈ	14.500.000 000	15.520.103.672	1.020.103.672	107,04%
			01	សហគ្រាសមជ្ឈិម	14.500.000.000	15.520.103.672	1.020.103 672	107,04%
		02		សហគ្រាសឯកជន	117.000.000.000	101.978.089.905	-15.021 910.095	87,16%
	05			ពន្ធលើផលខុននៃដីធ្លី - ផ្ទះសម្បែង	11.500 000.000	12.136.640.967	636.640 967	105,54%
11				ជំពូក១១: ពន្ធលើមេតិកភ័ណ្ឌ				
	01			ពន្ធប្រថាប់ត្រា				
		01		ពន្ធផ្ទេរមតិករវាងអ្នកនៅរស់				
		02.		ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់				
12				ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវា	780.000.000.000	902.313.173.574	122.313.173.574	115,68%
	01			អាករលើផលរបរ: របបផ្ទៃក្នុង	9 600.000 000	7.467.806.056	-2.132.193.944	77,79%
		01		សហគ្រាសសាធារណៈ		23.322.727	23.322.727	
			01	សហគ្រាសមជ្ឈិម		23.322.727	23.322.727	
		02		សហគ្រាសឯកជន	9.600 000.000	7.444.483.329	-2.155 516 671	77,55%
	02			អាករលើតំលៃបន្ថែម : របបផ្ទៃក្នុង	116.500.000.000	186.205.091.247	69.705.091 247	159,83%
		01		សហគ្រាសសាធារណៈ	15 000.000 000	13.639.501.815	-1.360.498 185	90,93%
		02		សហគ្រាសឯកជន	101.500.000.000	172.565.589 432	71.065.589.432	170,02%
	03			ពន្ធប៉ាតង់		54.344.696	54 344.696	
	04			អាករពិសេសលើទំនិញមួយចំនួន និងសេវាកម្ម	262 500.000 000	304.407.550.865	41.907.550 865	115,96%
		01		របបផ្ទៃក្នុង	44.500 000.000	49.031.864.591	4.531.864 591	110,18%
		02		របបនៃការនាំចូល	218.000 000.000	255 375.686.274	37.375 686.274	117,14%
	0S			អាករលើតំលៃបន្ថែម : របបនាំចូល	391 400 000.000	404.178.380.710	12.778.380.710	103,26%
		01		សហគ្រាសប្រេងឥន្ធនៈ	122 000.000.000	118.163.940 187	-3.836.059 813	96,86%
		02		សហគ្រាសដទៃទៀត	269 400 000.000	286.014 440.523	16 614.440.523	106,17%
13				ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស	510.600 000.000	513 321.944.369	2.721 944.369	100,53%
	01			ពន្ធ និង អាករគយពីការនាំចូល	490.500.000.000	491.272.082.330	772.082 330	100,16%
		01		ពន្ធគយពីការនាំចូល	228 000.000.000	235.096.965.096	7.096.965.096	103,11%
		[illegible]		[illegible]កម្មលើការងារគយក្នុងការនាំចូល	22 500.000.000	21.101.187.884	-1 398.812.116	93,78%
		04		[illegible]លើផលិតផលប្រេងកាត	170 000.000.000	133.153.959.596	-36.846 040.404	78,33%
		05		អាក[illegible]ពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវថ្នល់	70 000 000 000	101.919.969.754	31.919 969.754	145,60%
		[illegible]		អាករ[illegible]ចេញ	14 600 000 000	19.344.857 471	4.744.857 471	132,50%

ROYAUME DU CAMBODGE · REGISTRE du PALAIS ROYAL

ការគ្រប់គ្រងឆ្នាំ ២០០៤

តារាង "ក"

ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: រៀល

ជំពូក	គណនី	អនុគណនី	កញ្ចប់ចំណូល	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៤	ការអនុវត្តន៍ថវិកា ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ	
							លើស (+) ខ្វះ (-)	ភាគរយ
13	02	01		អាករគយពីការនាំចេញ	14 600.000.000	19.344.857.471	4.744.857.471	132,50%
			01	អាករលើការនាំឈើចេញ	3.600.000.000	3.385.233.891	-214.766.109	94,03%
			02	អាករលើការនាំកៅស៊ូចេញ	9.500.000.000	15.461.787.706	5.961.787.706	162,76%
			03	អាករលើការនាំផលិតផលផ្សេងៗចេញ	1.500.000.000	497.835.874	-1.002.164.126	33,19%
	03			ការផាកពិន័យរបស់គយ	5.500.000.000	2.705.004.568	-2.794.995.432	49,18%
14				ជំពូក១៤: ចំណូលសារពើពន្ធផ្សេងៗទៀត	7 700.000.000	3.766.024.804	-3.933.975.196	48,91%
	01			ពន្ធតែមប្រ៍	1 800.000.000	1.564.445.871	-235.554.129	86,91%
	04			ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ	5 900.000.000	2.197.153.453	-3.702.846.547	37,24%
	05			អាករលើយានយន្តនាំចូលដោយផ្ទុយនឹងច្បាប់		4.425.480	4.425.480	
				ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ	631.000.000.000	529.791.973.374	-101.208.026.626	83,96%
20				ជំពូក២០: ផលទុននៃទ្រព្យសម្បត្តិរដ្ឋ	207.270.000.000	114.057.840.930	-93.212.159.070	55,03%
	01			ផលនេសាទ	8.500.000.000	7.049.317.500	-1 450.682.500	82,93%
	02			ផលព្រៃឈើ	30.500.000.000	1.786.914 820	-28.713.085 180	5,86%
	03			ផលទុនបានមកពីសហគ្រាសសាធារណៈ	133.265.000.000	76.686.390.181	-56.578.609.819	57,54%
		01		ការជួលភោគចក្រសហគ្រាស	11.065.000.000	5.862.185.175	-5.202.814.825	52,98%
			01	សហគ្រាសមធ្យម	11.065.000.000	5.862.185.175	-5.202.814.825	52,98%
		02		ការបង់ប្រាក់លែសំឡើងវិញ	492.000.000	50.120.495	-441.879.505	10,19%
			01	សហគ្រាសមធ្យម	485.000.000	50.120.495	-434.879.505	10,33%
			02	សហគ្រាសខេត្តនានា	7.000.000		-7.000.000	0,00%
		05		ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ	2.425.000.000	514.336.621	-1.910.663.379	21,21%
		06		ផលទុនរបស់អាកាសចរណ៍ស៊ីវិល	50.000.000.000	26.905.346.444	-23.094.653.556	53,81%
		07		ផលទុននៃសកម្មភាពភាពយន្ត		6.125.000	6.125.000	
		08		ចំណូលសកម្មភាពទេសចរណ៍	52.000.000.000	28.832.580.201	-23.167 419.799	55,45%
		09		ការលក់សំភារៈបរិក្ខា	100.000.000	238.009.000	138.009.000	238,01%
		10		ការជួលសំភារៈបរិក្ខា	5.000.000	4.852.300	-147 700	97,05%
		11		ផលនៃការជីកជញ្ជូនទំនិញ	20.000.000	12.259 600	-7.740 400	61,30%
		12		ផលនៃប្រតិបត្តិការពាណិជ្ជកម្ម		2.640.000	2.640.000	
		13		ការផ្គត់ផ្គង់អគ្គិសនីទៅតាមខេត្តនានា	4.000.000		-4 000 000	0,00%
		14		ផលទុកនៃរោងចក្រទឹក	4.000.000		-4.000 000	0,00%
		15		មូលនិធិថែទាំផ្លូវថ្នល់	15.000.000.000	12.035.000.000	-2 965.000 000	80,23%
		20		ផលទុនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ	2 150.000.000	2.222.935.345	72.935.345	103,39%
	04			កំរៃយកមុនក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ	5 935.000.000	7.897.845.889	1.962.845.889	133,07%
		02		សម្បទានដីរ៉ែ	1 935.000.000	1.306.068.463	-628.931 537	67,50%
		10		សម្បទានផ្សេងៗទៀត	4 000.000.000	6.591 777.426	2.591 777 426	164,79%
	06			ការជួលអចលនវត្ថុ	28.000.000.000	19.853.628.388	-8.146.371 612	70,91%
	07			ផលពីការលក់ផ្លែកគយ	500.000.000	524.904.952	24.904 952	104,98%
	09			ផលពីការលក់ចលនវត្ថុចាស់របស់រដ្ឋ	50.000.000	250.889.200	200.889 200	501,78%
	20			ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ	520.000.000	7.950.000	-512.050.000	1,53%
21				ជំពូក២១: ចំណូលផ្សេងៗទៀតមិនមែនសារពើពន្ធ	423.730.000.000	415.734.132.444	-7.995.867 556	98,11%
	01			ផលពន្ធប្រៃសណីយ៍ និង ទូរគមនាគមន៍	160.000 000.000	94.238.555.307	-65.761.444 693	58,90%

ការគ្រប់គ្រងឆ្នាំ ២០០៤
តារាង "ក"
ចំណូលថវិកាជាតិនៃរបស់រដ្ឋ

ឯកតា: រៀល

ជំពូក	គណនី	អនុគណនី	អនុគណនីរង	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៤	ការអនុវត្តជាក់ស្តែង ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ លើស (+) ខ្វះ (-)	ភាគរយ
	02			ផលទុនវិទ្យុ ទូរទស្សន៍ ការផ្សាយ	640.000.000	44.692.500	-595.307.500	6,98%
	03			ចំណូលនៃសេវាកម្មសាធារណៈ	255.995.000.000	252.830.156.021	-3.164.843.979	98,76%
		01		កំរៃនៃការថែទាំ	100.000.000	141.317.607	41.317.607	141,32%
21	03	03		ចំណូលពីទិដ្ឋាការ	80.000.000.000	62.163.573.753	-17 836.426.247	77,70%
		04		ផលទុននៃសកម្មភាពវប្បធម៌	530.000.000	357.151.063	-172.848.937	67,39%
		05		ពន្ធលើអាជ្ញាប័ណ្ណនាំឈើចេញ	700.000.000	23.567.104	-676.432.896	3,37%
		06		ការត្រួតពិនិត្យគុណភាពផលិតផល	10.410.000.000	17.939.598.786	7.529.598.786	172,33%
		07		ពន្ធលើការបង្កើតសហគ្រាស	450.000.000	431.800.000	-18 200.000	95,96%
		10		លតាប័ត្រ និង លិខិតបោះពុម្ពផ្សេងៗរបស់គយ	2 700 000.000	3.264.076.689	564.076.689	120,89%
		11		ឯកសារផ្សេងៗទៀត	320.000.000	156.567.000	-163.433.000	48,93%
		12		ការលក់ឯកសារ និង លិខិតបោះពុម្ពរបស់ពន្ធដារ	1 500 000 000	1.557.611.600	57.611.600	103,84%
		13		ផលនៃការលក់ផ្លាកលេខ	625.000.000	34.697.875	-590.302.125	5,55%
		16		ចំណូលពីឆ្នោត	1.400.000.000	2.088 849.328	688.849.328	149,20%
	03	17		កំរៃគូតាចំពោះផលិតផលវាយនភ័ណ្ឌនាំចេញ	115.000.000.000	122.893.702.000	7.893.702.000	106,86%
			01	ដេញថ្លៃកូតា	65.000.000.000	88.724.702.000	23.724.702.000	136,50%
			02	អាជ្ញាប័ណ្ណនាំចេញសំលៀកបំពាក់	50.000.000.000	34.169.000.000	-15.831.000.000	68,34%
		18		ចំណូលពីកាស៊ីណូ	40.000.000.000	37.184.894.984	-2.815 105.016	92,96%
		19		សេវាកម្មស៊ីវិលយានដ្ឋាន	1.000.000.000	757.689.900	-242.310.100	75,77%
		30		ចំណូលផ្សេងៗទៀតរបស់សេវាកម្មសាធារណៈ	1.260.000.000	3.835.058 332	2.575.058.332	304,37%
	04			ប្រាក់ចំណេញរតនាគារ និង ការប្រាក់ផ្សេងៗ		4.337 916.338	4.337.916.338	
	05			ចំណូលក្រៅសារពើពន្ធរបស់ខេត្តនានា		3.809.086 181	3.809.086.181	
	06			ប្រាក់ចំណេញធនាគារជាតិ	5.000 000.000	2.654 902.348	-2.345.097.652	53,10%
	07			ចំណូលពីអតិរេកនៃថវិកាខេត្ត ក្រុង		16 941 992.450	16.941.992 450	
	20			ចំណូលផ្សេងៗក្រៅពីសារពើពន្ធ	2.095 000.000	40 876 831 299	38 781.831 299	1951,16%
				ខ. សរុបចំណូលជាមូលធន	210.000.000.000	63.957.467.155	-146.042.532.845	30,46%
				ប្រភេទទី៣: ចំណូលជាមូលធន	210.000.000.000	63.957 467.155	-146.042.532.845	30,46%
30				ជំពូក៣០: ចំណូលផ្ទៃក្នុងជាមូលធន	25.000.000.000	19.454 615 034	-5.545.384.966	77,82%
	01			ការលក់ទ្រព្យសម្បត្តិនៃមូលធនថេរ		649.213.277	649 213 277	
	04			ផលឯកជនភាវូបនីយកម្ម	25 000.000.000	4 976 271.552	-20 023.728.448	19,91%
	15			ចំណូលពីការខ្ចីបុលក្នុងប្រទេស		13.829.130.205	13.829.130.205	
31				ជំពូក៣១: អំណោយពីបរទេស	120.000.000.000	11 834 091 683	-108.165.908.317	9,86%
	02			មូលនិធិបដិភាគ	120.000.000.000	1.229.308 350	-118.770.691.650	1,02%
		01		ជប៉ុន		1 229.308 350	1.229 308.350	
	03			អំណោយផ្សេងៗទៀតពីបរទេស		10 604.783.333	10.604.783.333	
		09		សហគមន៍អឺរ៉ុប		10.604 783.333	10.604.783.333	
32				ជំពូក៣២: ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីបុល	65.000.000.000	32.668 760 438	-32 331 239.562	50,26%
	02			ប្រាក់កម្ចីពីបរទេស	65 000.000 000	32 668 760 438	-32.331.239.562	50,26%
		01		ប្រាក់ឥណទានពីបរទេសបានមកពីស្ថាប័នអន្តរជាតិនានា	65.000 000 000	32 668 760 438	-32 331.239.562	50,26%
			01	ធនាគារពិភពលោក	30.000.000.000		-30.000 000 000	0,00%

ការគ្រប់គ្រងឆ្នាំ ២០០៤

តារាង "ក"

ចំណូលថវិកាទូទៅរបស់រដ្ឋ

ឯកតា: រៀល

ជំពូក	ប្រការ	កថាខណ្ឌ	អនុកថាខណ្ឌ	ការរាយមុខចំណូល	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០០៤	ការអនុវត្តន៍ថវិកា ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ លើស (+) ខ្វះ (-)	ភាគរយ
				មូលនិធិបដិភាគ	30.000 000.000		-30.000 000 000	0,00%
			02	ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍	35.000.000.000	32.668.760.438	-2.331.239 562	93,34%
				មូលនិធិបដិភាគ	35.000.000.000	32.668.760.438	-2.331.239.562	93,34%
II. សរុបចំណូលថវិកាអនុវត្តក្រៅរតនាគារជាតិ					700.000.000.000	927.436.000.000	227.436.000.000	132,49%
				សរុបចំណូលជាមូលធន	700.000.000.000	927.436.000.000	227.436.000.000	132,49%
				ប្រភេទទី៣: ចំណូលជាមូលធន	700.000.000.000	927.436.000.000	227.436.000.000	132,49%
31				ជំពូក៣១: អំណោយពីបរទេស	400.000.000.000	391.157.000.000	-8.843.000.000	97,79%
	03			អំណោយផ្សេងៗទៀតពីបរទេស	400.000.000.000	391.157.000.000	-8.843.000.000	97,79%
		01		ជប៉ុន		391.157.000.000	391.157.000.000	
32				ជំពូក៣២: ប្រភពទ្រព្យសម្បត្តិបានមកពីការខ្ចីបុល	300.000.000.000	536.279.000.000	236 279.000.000	178,76%
	02			ប្រភពទុនខ្ចីពីបរទេស	300.000.000.000	426.618.000.000	126 618.000.000	142,21%
		01		ប្រភពទុនខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា	300.000.000.000	426.618.000.000	126.618.000.000	142,21%
			01	ធនាគារពិភពលោក	100.000.000.000	177.614.000.000	77.614.000 000	177.61%
				គំរោងខ្ចី	100.000.000.000	177.614.000.000	77 614.000.000	177,61%
			02	ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍	200.000.000.000	243.173.000.000	43.173.000.000	121,59%
				គំរោងខ្ចី	200.000.000.000	243.173.000 000	43.173.000.000	121,59%
			03	ទ្វេភាគី		115.492.000.000	115.492.000.000	
				....				

ការគ្រប់គ្រងឆ្នាំ ២០០៤
តារាង "ខ"
ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា: រៀល

ក្រសួងនានា - ផ្នែក - ជំពូក	ច្បាប់ថវិកា ឆ្នាំ ២០០៤	ការអនុវត្តន៍ ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ: លើស (+) ខ្វះ (-)	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ: ភាគរយ
សរុបរួមចំណាយថវិកា (I+II)	3.011.000.000.000	3.006.221.335.742	-4.778.664.258	99,84%
I. កិច្ចប្រតិបត្តិការតនាគារជាតិ (ក+ខ)	2.311.000.000.000	2.078.785.335.742	-232.214.664.258	89,95%
- សរុបចំណាយចរន្ត	1.891.000.000.000	1.746.261.688.992	-144.738.311.008	92,35%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	664.485.000.000	639.705.198.911	-24.779.801.089	96,27%
ជំពូក ១១ ចំណាយដំណើរការ	598 980.000.000	565.042.007.833	-33.937.992.167	94,33%
ជំពូក ១២ ប្រាក់ឧបត្ថម្ភ អង្គភាពសាធារណៈរដ្ឋបាល	122.225.000.000	113.975.057.774	-8.249.942.226	93,25%
ជំពូក ១៣ សកម្មភាពនៃកម្មវិធី	180.160.000.000	152.633 247.435	-27 526.752.565	84,72%
ជំពូក ២០ ការប្រាក់នៃការខ្ចី	45.000.000.000	48.598.839.627	3.598.839.627	108,00%
ជំពូក ៣០ អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	16.685.000.000	63.807.433 271	47 122.433.271	382,42%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	134.210.000.000	141.237 235.536	7.027.235.536	105,24%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	10.255.000.000	10.269.351.310	14.351.310	100,14%
ជំពូក ៤០ ចំណាយផ្សេងៗ	99.000.000.000	10.993 317.295	-88.006.682.705	11,10%
ជំពូក ៤១ ចំណាយមិនបានគ្រោងទុក	20.000.000.000		-20.000.000.000	0,00%
សរុបចំណាយជាមូលធន	420 000.000.000	332.523.646 750	-87.476.353.250	79,17%
ជំពូក ៥០ ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	325.000.000.000	296.478.660.554	-28.521.339.446	91,22%
ជំពូក ៥០.១ សាងសង់ និង ទិញសំភារៈ	60.000.000.000	144 371.472.272	84.371.472.272	240,62%
ជំពូក ៥០.២ បដិភាគក្នុងស្រុកលើហិរញ្ញប្បទានក្រៅប្រទេស	80.000.000.000	85.123.033.430	5.123.033.430	106,40%
ជំពូក ៥០.៣ វិនិយោគដោយមូលនិធិបរទេស	185 000.000.000	66.984.154.852	-118.015.845.148	36,21%
ជំពូក ៥៣ ការទូទាត់បំណុល	95.000.000.000	36.044.986.196	-58.955.013.804	37.94%
ក. សរុបរដ្ឋបាលស៊ីវិល	1.877.900.000.000	1.655.671.771.210	-222.228.228.790	88,17%
សរុបចំណាយចរន្ត	1.457.900.000.000	1.323.442.136 706	-134.457 863.294	90,78%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	367.535.000.000	343.618.497 111	-23.916.502.889	93,49%
ជំពូក ១១ ចំណាយដំណើរការ	478.930.000 000	453.962.276.998	-24.967.723.002	94,79%
ជំពូក ១២ ប្រាក់ឧបត្ថម្ភ អង្គភាពសាធារណៈរដ្ឋបាល	122.225.000.000	113.975 057 774	-8 249.942.226	93,25%
ជំពូក ១៣ សកម្មភាពនៃកម្មវិធី	180.160 000.000	152.633 247.435	-27 526.752.565	84,72%
ជំពូក ២០ ការប្រាក់នៃការខ្ចី	45.000 000.000	48.598.839 627	3.598.839.627	108,00%
ជំពូក ៣០ អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	16.685.000.000	63 807.433 271	47.122.433.271	382,42%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	118.200.000.000	125.665.953.545	7 465.953.545	106,32%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	10.165.000.000	10.187.513 650	22.513.650	100,22%
ជំពូក ៤០ ចំណាយផ្សេងៗ	99.000.000.000	10 993.317 295	-88 006.682 705	11,10%
ជំពូក ៤១ ចំណាយមិនបានគ្រោងទុក	20.000.000.000		-20.000 000.000	0,00%
សរុបចំណាយជាមូលធន	420.000.000.000	332.229.634.504	-87 770.365.496	79,10%
ជំពូក ៥០ ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	325.000 000.000	296.184.648.308	-28 815 351.692	91,13%
ជំពូក ៥០.១ សាងសង់ និង ទិញសំភារៈ	60 000 000.000	144.077.460.026	84 077 460.026	240,13%
ជំពូក ៥០.២ បដិភាគក្នុងស្រុកលើហិរញ្ញប្បទានក្រៅប្រទេស	80 000.000.000	85.123.033.430	5 123.033.430	106,40%
ជំពូក ៥០.៣ វិនិយោគដោយមូលនិធិបរទេស	185.000.000.000	66.984.154 852	-118.015 845.148	36,21%

ការគ្រប់គ្រងឆ្នាំ ២០០៤
តារាង "ខ"
ចំណាយថវិកាចរន្តរបស់រដ្ឋ

ឯកតាៈ រៀល

ក្រសួងនានា - ផ្នែក - ជំពូក	ច្បាប់ថវិកា ឆ្នាំ ២០០៤	ការអនុវត្តន៍ ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ លើស (+) ខ្វះ (-)	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ ភាគរយ
ជំពូក ៥៣ ការទូទាត់បំណុល	95.000.000.000	36.044.986.196	-58.955.013.804	37,94%
ក.១. សរុបរដ្ឋបាលកណ្តាលស៊ីវិល	1.425.225.000.000	1.224.332.866.626	-200.892.133.374	85,90%
សរុបចំណាយចរន្ត	1.005.225.000.000	892.103.232.122	-113.121.767.878	88,75%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	116.970.000.000	115.091.787.380	-1.878.212.620	98,39%
ជំពូក ១១ ចំណាយដំណើរការ	398.105.000.000	379.882.390.851	-18.222.609.149	95,42%
ជំពូក ១២ ប្រាក់ឧបត្ថម្ភ អង្គភាពសាធារណៈរដ្ឋបាល	122 225.000.000	113.975.057.774	-8 249.942.226	93,25%
ជំពូក ១៣ សកម្មភាពនៃកម្មវិធី	155.760.000.000	131.443 321.630	-24 316.678.370	84,39%
ជំពូក ២០ ការប្រាក់នៃការខ្ចី	45.000.000.000	48.598.839.627	3.598.839.627	108,00%
ជំពូក ៣០ អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	11.940.000.000	59.783.583.482	47.843.583.482	500,70%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	26.060.000.000	22.147.420.433	-3.912.579.567	84,99%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	10.165.000.000	10.187.513.650	22.513.650	100,22%
ជំពូក ៤០ ចំណាយផ្សេងៗ	99.000.000.000	10.993.317.295	-88.006.682.705	11,10%
ជំពូក ៤១ ចំណាយមិនបានគ្រោងទុក	20.000.000.000		-20.000.000.000	0,00%
សរុបចំណាយជាទុនធន	420.000.000.000	332.229.634 504	-87.770.365.496	79,10%
ជំពូក ៥០ ការវិនិយោគដោយហិរញ្ញប្បទានក្នុងស្រុក	325.000.000.000	296.184.648.308	-28.815.351.692	91,13%
ជំពូក ៥០.១ សាងសង់ និង ទិញសំភារៈ	60.000.000.000	144.077.460.026	84.077.460.026	240,13%
ជំពូក ៥០.២ បដិភាគក្នុងស្រុកលើហិរញ្ញប្បទានក្រៅប្រទេស	80.000.000.000	85.123.033.430	5.123.033.430	106,40%
ជំពូក ៥០.៣ វិនិយោគដោយមូលនិធិបរទេស	185.000.000.000	66.984.154.852	-118.015.845.148	36,21%
ជំពូក ៥៣ ការទូទាត់បំណុល	95.000.000.000	36.044.986.196	-58.955.013.804	37,94%
ក.២. សរុបមន្ទីរនានាតាមខេត្ត-ក្រុង	452.675.000 000	431.338.904.584	-21.336.095.416	95,29%
សរុបចំណាយចរន្ត	452.675.000.000	431.338.904.584	-21.336.095.416	95,29%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	250.565.000.000	228.526 709.731	-22.038.290.269	91,20%
ជំពូក ១១ ចំណាយដំណើរការ	80 825 000.000	74.079.886.147	-6.745.113.853	91,65%
ជំពូក ១៣ សកម្មភាពនៃកម្មវិធី	24.400.000.000	21.189.925.805	-3.210.074.195	86,84%
ជំពូក ៣០ អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	4.745.000.000	4 023 849.789	-721.150.211	84,80%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	92.140.000.000	103.518.533 112	11.378.533.112	112,35%
ខ. សរុបការពារ - សន្តិសុខ	433.100.000.000	423.113.564.532	-9.986 435.468	97,69%
សរុបចំណាយចរន្ត	433.100.000.000	422.819.552.286	-10.280.447 714	97,63%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	296.950.000.000	296.086.701.800	-863.298.200	99,71%
ជំពូក ១១ ចំណាយដំណើរការ	120.050 000.000	111.079.730.835	-8 970.269 165	92,53%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	16.010.000.000	15 571.281.991	-438.718.009	97,26%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	90.000.000	81 837.660	-8.162.340	90,93%
សរុបចំណាយជាទុនធន		294.012.246	294.012.246	
ជំពូក ៥០.១ សាងសង់ និង ទិញសំភារៈ		294.012.246	294.012.246	
II. កិច្ចប្រតិបត្តិការអនុវត្តក្រៅរតនាគារជាតិ	700.000.000.000	927.436.000.000	227.436.000.000	132,49%
ជំពូក ៥១ វិនិយោគលើហិរញ្ញប្បទានក្រៅប្រទេស	700.000.000.000	927.436.000.000	227.436.000 000	132,49%

ការគ្រប់គ្រងឆ្នាំ ២០០៤
តារាង "ខ"
ចំណាយថវិកាតាមទៅរបស់រដ្ឋ

ឯកតា: រៀល

ក្រសួងនានា - ផ្នែក - ជំពូក	ច្បាប់ថវិកា ឆ្នាំ ២០០៤	ការអនុវត្តន៍ ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ	
			លើស (+) ខ្វះ (-)	ភាគរយ
សរុបរួមចំណាយថវិកា	3.011.000.000.000	3.006.221.335.742	-4.778.664.258	99,84%
០១ - ព្រះបរមរាជវាំង	22.200.000.000	22.388.479.936	188.479.936	100,85%
សរុបចំណាយចរន្ត	22.200.000.000	22.375.047.976	175.047.976	100,79%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	7.000.000.000	7.316.320.624	316.320.624	104,52%
ជំពូក ១១ ចំណាយដំណើរការ	5 260 000 000	5.180.792.408	-79.207.592	98,49%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	9.940.000.000	9 877.934.944	-62.065.056	99,38%
សរុបចំណាយជាមូលធន		13.431.960	13.431.960	
ជំពូក ៥០ ២ បរិភាគក្នុងស្រុកលើហិរញ្ញប្បទានក្រៅប្រទេស		13.431.960	13 431.960	
០២ - រដ្ឋសភាជាតិ	35.500.000.000	44.120.240.271	8.620.240.271	124,28%
សរុបចំណាយចរន្ត	35.500.000.000	42.120.240.271	6.620.240 271	118,65%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	16.460.000.000	16.928.710.920	468.710 920	102,85%
ជំពូក ១១ ចំណាយដំណើរការ	17 130.000.000	23.316.529.351	6.186 529.351	136,12%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	1 660.000.000	1.660.000.000	0	100,00%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	250.000 000	215.000 000	-35.000.000	86,00%
សរុបចំណាយជាមូលធន		2.000.000.000	2.000.000.000	
ជំពូក ៥០.១ សាងសង់ និង ទិញសំភារៈ		2.000.000.000	2.000.000.000	
០៣ - ព្រឹទ្ធសភា	18.700.000.000	17.916.983.166	-783.016.834	95,81%
សរុបចំណាយចរន្ត	18.700.000.000	17.916.983.166	-783.016.834	95,81%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	7.710.000.000	6.941.597.800	-768.402.200	90,03%
ជំពូក ១១ ចំណាយដំណើរការ	9.040.000 000	9.025.385.366	-14.614.634	99,84%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	1.950.000.000	1.950.000.000	0	100,00%
០៤ - ក្រុមប្រឹក្សាធម្មនុញ្ញ	3.400.000 000	3 361 279.240	-38.720.760	98,86%
សរុបចំណាយចរន្ត	3.400.000 000	3 361.279.240	-38 720.760	98,86%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	1.420.000.000	1.381.279.240	-38 720.760	97,27%
ជំពូក ១១ ចំណាយដំណើរការ	1.850.000 000	1.850.000.000	0	100,00%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	125 000.000	125.000.000	0	100,00%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	5 000.000	5.000.000	0	100,00%
០៥ - គណៈរដ្ឋមន្ត្រី	71 100 000 000	115 350.303.973	44 250 303.973	162,24%
១. ទីស្តីការគណៈរដ្ឋមន្ត្រី	57 300 000.000	104.493.808.497	47.193.808 497	182,36%
សរុបចំណាយចរន្ត	57.300 000 000	81.948.051.443	24.648.051 443	143,02%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	6 300.000 000	6.835 295 028	535 295 028	108,50%
ជំពូក ១១ ចំណាយដំណើរការ	26.550 000.000	52 365.175.067	25.815 175.067	197,23%
ជំពូក ១២ ប្រាក់ឧបត្ថម្ភ អង្គភាពសាធារណៈរដ្ឋបាល	16.750 000 000	15.773.356.811	-976.643.189	94,17%
ជំពូក ៣០ អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច	5 250 000.000	4 958.218.030	-291.781.970	94,44%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	1 500 000 000	1.059.888.661	-440.111 339	70,66%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	950 000.000	956.117.846	6 117 846	100,64%
សរុបចំណាយជាមូលធន		22.545.757.054	22.545.757 054	
ជំពូក ៥០.១ សាងសង់ និង ទិញសំភារៈ		3 135.569.854	3.135.569.854	
ជំពូក ៥០ ២ បរិភាគក្នុងស្រុកលើហិរញ្ញប្បទានក្រៅប្រទេស		11.751 509.787	11.751.509.787	
ជំពូក ៥០.៣ វិនិយោគជាមូលនិធិបរទេស		7.658.677.413	7.658.677.413	
២. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ	1 300.000.000	1.502.316.302	202.316 302	115,56%

ការគ្រប់គ្រងឆ្នាំ ២០០៤
តារាង "ខ"
ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា: រៀល

ក្រសួងនានា - ជំពូក - ជំពូក	ច្បាប់ថវិកា ឆ្នាំ ២០០៤	ការអនុវត្តន៍ ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ លើស (+) ខ្វះ (-)	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ ភាគរយ
សរុបចំណាយចរន្ត	1.300.000.000	1.223.273.802	-76.726.198	94,10%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	465.000.000	449.198.200	-15.801.800	96,60%
ជំពូក ១១ ចំណាយដំណើរការ	830.000 000	773 275.602	-56.724.398	93,17%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	5.000.000	800.000	-4.200.000	16,00%
សរុបចំណាយជាមូលធន		279.042.500	279.042.500	
ជំពូក ៥០.១ សាងសង់ និង ទ្រព្យសម្ភារ:		279.042.500	279.042.500	
៣. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	8.600.000.000	6.191 866.323	-2 408 133.677	72,00%
សរុបចំណាយចរន្ត	8.600.000.000	6.024.988.523	-2.575 011.477	70,06%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	2.500.000.000	2.945.526.577	445.526.577	117,82%
ជំពូក ១១ ចំណាយដំណើរការ	5 075.000.000	2.802.022 038	-2.272 977 962	55,21%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	25 000.000		-25.000.000	0,00%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	1.000.000.000	277.439.908	-722.560.092	27,74%
សរុបចំណាយជាមូលធន		166.877.800	166 877.800	
ជំពូក ៥០.២ បដិភាគក្នុងស្រុកលើហិរញ្ញប្បទានក្រៅប្រទេស		166.877.800	166.877.800	
៤. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	3.900.000 000	3.162.312.851	-737.687 149	81,08%
សរុបចំណាយចរន្ត	3.900.000.000	3.162.312.851	-737.687.149	81,08%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	185.000.000	180 358.056	-4 641.944	97,49%
ជំពូក ១១ ចំណាយដំណើរការ	3.700.000.000	2.981.954.795	-718.045.205	80,59%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	15.000 000		-15.000.000	0,00%
០៦ - ក្រសួងការពារជាតិ	278.000.000 000	271.738.909 407	-6.261.090.593	97,75%
សរុបចំណាយចរន្ត	278.000.000 000	271.738.909.407	-6.261.090.593	97,75%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	205.300 000 000	205.167.365 000	-132.635.000	99,94%
ជំពូក ១១ ចំណាយដំណើរការ	63.700.000 000	57 171 242.407	-6 528 757.593	89,75%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	9.000 000.000	9 400.302.000	400 302 000	104,45%
០៧ - ក្រសួងមហាផ្ទៃ	172 700.000 000	183 661.266 808	10 961.266.808	106,35%
១. សន្តិសុខសាធារណៈ	155 100 000.000	151 374.655.125	-3 725 344 875	97,60%
សរុបចំណាយចរន្ត	155 100 000 000	151.080 642.879	-4.019.357 121	97,41%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	91 650 000 000	90 919 336 800	-730 663 200	99,20%
ជំពូក ១១ ចំណាយដំណើរការ	56 350 000 000	53.908 488 428	-2 441 511.572	95,67%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	7 010.000 000	6.170.979 991	-839 020.009	88,03%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	90.000 000	81.837.660	-8 162 340	90,93%
សរុបចំណាយជាមូលធន		294.012 246	294.012 246	
ជំពូក ៥០.១ សាងសង់ និង ទ្រព្យសម្ភារ:		294 012.246	294.012.246	
២. រដ្ឋបាលទូទៅ	17.600.000 000	32.286 611 683	14.686 611 683	183,45%
សរុបចំណាយចរន្ត	17 600 000.000	17 154.991 876	-445 008.124	97,47%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	3.420.000.000	4.399.441 471	979 441.471	128,64%
ជំពូក ១១ ចំណាយដំណើរការ	12.370.000.000	11.003.019.955	-1 366 980.045	88,95%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	1.800.000.000	1.748.521.450	-51 478 550	97,14%
ជំពូក ៣២ អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ	10.000.000	4.009.000	-5 991.000	40,09%
សរុបចំណាយជាមូលធន		15.131 619.807	15 131.619.807	
ជំពូក ៥០.១ សាងសង់ និង ទ្រព្យសម្ភារ:		12.279.555 720	12 279.555.720	

ការគ្រប់គ្រងឆ្នាំ ២០០៤

តារាង "ខ"

ចំណាយថវិកាទូទៅរបស់រដ្ឋ

ឯកតា: រៀល

ក្រសួងនានា ~ ផ្នែក ~ ជំពូក	ច្បាប់ថវិកា ឆ្នាំ ២០០៤	ការអនុវត្តន៍ ឆ្នាំ ២០០៤	ការអនុវត្តន៍ / ច្បាប់ហិរញ្ញវត្ថុ លើស (+) ខ្វះ (-)	ភាគរយ
ជំពូក ៥០.២ បដិភាគក្នុងស្រុកលើហិរញ្ញប្បទានក្រៅប្រទេស		2.852.064.087	2.852.064.087	
០៨ - ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	2.870.000.000	2 192.764.548	-677.235.452	76,40%
១. ក្រសួង	2.070.000.000	1.746.750 228	-323.249.772	84,38%
សរុបចំណាយចរន្ត	2.070.000.000	1.746.750.228	-323.249.772	84,38%
ជំពូក ១០ បៀវត្ស និង ប្រាក់បំណាច់	695.000.000	659.540.700	-35.459.300	94,90%
ជំពូក ១១ ចំណាយដំណើរការ	1.360.000.000	1.082.090.128	-277.909.872	79,57%
ជំពូក ៣១ អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច	15.000.000	5.119.400	-9.880.600	34,13%
៩. ខេត្តនានា	800.000.000	446.014.320	-353.985.680	55,75%
២. ទណ្ឌិតឈ្មោះ **ង៉ែន ភាគ** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-០១-២០០១ ពីបទចាប់មនុស្សជំរិតទារប្រាក់ និងធ្វើមនុស្សឃាត ដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៨ "ក" ចុះថ្ងៃទី ២៩-៦-២០០១ របស់តុលាការខេត្តកំពង់ចាម ។

ROYAUME DU CAMBODGE * ROYAL *

៧_ ទណ្ឌិតឈ្មោះ **អ៊ឹម សុខន** ភេទប្រុស អាយុ ៥១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៣-២០០០ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤២"ក" ចុះថ្ងៃទី ១៤-៧-២០០០ របស់តុលាការខេត្តកំពង់ចាម ។

៨_ ទណ្ឌិតឈ្មោះ **ខៀវ ឥទ្ធៈ** ភេទ ប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-០២-២០០១ ពីបទប្លន់មានបក្សពួក និង ប៉ុនប៉ងធ្វើឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៨-០១-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

៩_ ទណ្ឌិតឈ្មោះ **សួន ខាន់** ភេទប្រុស អាយុ ២២ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-០២-២០០១ ពីបទប្លន់មានបក្សពួក និង ប៉ុនប៉ងធ្វើឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៨-០១-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

១០_ ទណ្ឌិតឈ្មោះ **ភឿន ឌីម៉ង់** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-១០-២០០២ ពីបទប្លន់មានបក្សពួក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ១១ ចុះថ្ងៃទី ២៥-៤-២០០៣ របស់តុលាការខេត្តស្ទឹងត្រែង ។

១១_ ទណ្ឌិតឈ្មោះ **អ៊ុំ ទីរ៉ាត់** ហៅ **ខ្និះ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-១០-២០០២ ពីបទប្លន់មានបក្សពួក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៥-៤-២០០៣ របស់តុលាការខេត្តស្ទឹងត្រែង ។

១២_ ទណ្ឌិតឈ្មោះ **ស៊ុយ សុខឡុយ** ហៅ **ផាត សុជាតិ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-១១-២០០២ ពីបទប្លន់មានបក្សពួក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១ ចុះថ្ងៃទី ២៥-៤-២០០៣ របស់តុលាការខេត្តស្ទឹងត្រែង។

១៣_ ទណ្ឌិតឈ្មោះ **ទ្រាវ៉ូ សុវណ្ណា** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៤-៤-២០០០ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ ចុះថ្ងៃទី ០៦-៩-២០០០ របស់តុលាការខេត្តរតនគីរី ។

១៤_ ទណ្ឌិតឈ្មោះ **ជិន សួរ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-០១-១៩៩៧ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធដែលច្បាប់ហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២១-៣-១៩៩៧ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

១៥_ ទណ្ឌិតឈ្មោះ **ញ៉ាន យឿន** ភេទ ប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-៩-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធដែលច្បាប់ហាមឃាត់ ហើយត្រូវតុលាការសម្រេច

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះរាជវាំង

ផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ១៩-០១-២០០០ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

១៦. ទណ្ឌិតឈ្មោះ **ផន ទី** ហៅ **វី** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-៩-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធដែលច្បាប់ហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៨ ចុះថ្ងៃទី ១៩-០១-២០០០ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

១៧. ទណ្ឌិតឈ្មោះ **ខា ថន** ភេទ ប្រុស អាយុ ២៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-៧-១៩៩៨ ពីបទប្លន់ និងការកាន់កាប់អាវុធដែលច្បាប់ហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៨ ចុះថ្ងៃទី ២៥-៩-១៩៩៨ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

១៨. ទណ្ឌិតឈ្មោះ **ឃឹម ថៃ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-៩-២០០០ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និងក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩៤ ចុះថ្ងៃទី ១៣-១២-២០០០ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

១៩. ទណ្ឌិតឈ្មោះ **ឈុន សាមឌី** ភេទ ប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-៩-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និង ក្រុមជនប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រម លេខ ៣៩៤ ចុះថ្ងៃទី ១៣-១២-២០០០របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២០. ទណ្ឌិតឈ្មោះ **ឈុន ម៉ីន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៧-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៧ ចុះថ្ងៃទី ២០-១០-១៩៩៩ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២១. ទណ្ឌិតឈ្មោះ **ឈាន យ៉ុន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៧-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៧ ចុះថ្ងៃទី ២០-១០-១៩៩៩ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២២. ទណ្ឌិតឈ្មោះ **ឆាន សុខុន** ហៅ **វើន** ភេទ ប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅ ថ្ងៃទី ២៨-០២-២០០០ ពីបទឃាតកម្មគិតទុកជាមុន និងការកាន់កាប់អាវុធដែលច្បាប់ហាមឃាត់ ហើយ

ត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០២ ចុះថ្ងៃទី ២៥ -៨-២០០០ របស់តុលាការខេត្តតុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២៣~ ទណ្ឌិតឈ្មោះ **ហឿន សាម៉ុយ** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-១១-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ២៧-០១-២០០០ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២៤~ ទណ្ឌិតឈ្មោះ **រិត ជ្រឿយ** ហៅ **សួន ឡឿង** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-០២-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧ ចុះថ្ងៃទី ២៥-៣-១៩៩៩ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២៥~ ទណ្ឌិតឈ្មោះ **ឡាន ឡាយ** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-៩-២០០០ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលក្រមលេខ ៤៨ ចុះថ្ងៃទី ២៣-៣-២០០១ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ២៣ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១~ ទណ្ឌិតឈ្មោះ **សឿ ភូរីដេត** ហៅ **តូ រី** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៩-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ និង ប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៦ "ក" ចុះថ្ងៃទី ០១-៣-២០០១ របស់តុលាការខេត្តកំពង់ចាម ។

២~ ទណ្ឌិតឈ្មោះ **ខន សុវណ្ណារ៉ា** ហៅ **នន់** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៥-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ០៣-១២-២០០៤ របស់តុលាការខេត្តស្ទឹងត្រែង ។

៣~ ទណ្ឌិតឈ្មោះ **ជួត ញឹក** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៥-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ០៣-១២-២០០៤ របស់តុលាការខេត្តស្ទឹងត្រែង។

៤~ ទណ្ឌិតឈ្មោះ **ហេង ម៉ុនឡឿង** ហៅ **តិល** ភេទប្រុស អាយុ ៤៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-៧-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ ចុះថ្ងៃទី ០៣-១២-២០០៤ របស់តុលាការខេត្តស្ទឹងត្រែង ។

៣. ទណ្ឌិតឈ្មោះ **ឃាង សុខា** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-១២-១៩៩៣ ពីបទប្លន់ និងឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ១០-៣-១៩៩៤ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

៤. ទណ្ឌិតឈ្មោះ **មួង ឈឿន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-១២-១៩៩៣ ពីបទប្លន់ និងឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ១០-៣-១៩៩៤ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ២៥ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១. ទណ្ឌិតឈ្មោះ **ម៉ៅ ហាន** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី២៩-៧-១៩៩៥ ពីបទប្លន់ និងធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧"គ" ចុះថ្ងៃទី ០៣-០២-១៩៩៦ របស់តុលាការខេត្តកំពង់ចាម ។

២. ទណ្ឌិតឈ្មោះ **សា ញ៉ូ** ភេទស្រី អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៧-២០០០ ពីបទពង្រត់មនុស្សយកទៅលក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ០១"ក" ចុះថ្ងៃទី ០២-០១-២០០១ របស់តុលាការខេត្តកំពង់ចាម ។

៣. ទណ្ឌិតឈ្មោះ **សា មុំ** ភេទ ស្រី អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៧-២០០០ ពីបទពង្រត់មនុស្សយកទៅលក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ០១ "ក" ចុះថ្ងៃទី០២-០១-២០០១ របស់តុលាការខេត្តកំពង់ចាម ។

៤. ទណ្ឌិតឈ្មោះ **ប៊ូ គីមធី** ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៤-២០០១ ពីបទប្លន់ និង ធ្វើមនុស្សឃាតដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧៧ "ក" ចុះថ្ងៃទី ២៦-១០-២០០១ របស់តុលាការខេត្តកំពង់ចាម ។

៥. ទណ្ឌិតឈ្មោះ **ជី សារ៉េត** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥ -៤-២០០១ ពីបទប្លន់ និង ឃាតកម្មដោយគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១៧៧ "ក" ចុះថ្ងៃទី ២៦-១០-២០០១ របស់តុលាការខេត្តកំពង់ចាម ។

៦. ទណ្ឌិតឈ្មោះ **ជា សារ៉េត** ភេទ ប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី១៩-០១-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៥ "ក" ចុះថ្ងៃទី ២១-៦-២០០១ របស់តុលាការខេត្តកំពង់ចាម ។

CAMBODGE ROYAL

៥. ទណ្ឌិតឈ្មោះ **គូ ម៉្នា ម៉ុនចាន់** ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-៧-២០០៤ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៩ ចុះថ្ងៃទី ០៣-១២-២០០៤ របស់តុលាការខេត្តស្ទឹងត្រែង ។

៦. ទណ្ឌិតឈ្មោះ **សា រិធី ហៅ ខ្វិន** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១១-២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំតាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២២-០១-២០០២ របស់តុលាការខេត្តរតនគីរី ។

៧. ទណ្ឌិតឈ្មោះ **មេខ សុខជា** ភេទប្រុស អាយុ ២០ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៩-២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ឃ" ចុះថ្ងៃទី ១៤-៣-២០០២ របស់តុលាការខេត្តបាត់ដំបង ។

៨. ទណ្ឌិតឈ្មោះ **នួន សុធា ហៅ ទឹម សុធា** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៦-២០០៤ ពីបទសមគំនិតក្នុងអំពើចោរកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០២ "គ" ចុះថ្ងៃទី ២៧-១០-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

៩. ទណ្ឌិតឈ្មោះ **នួន អូន ហៅ ម៉ៅ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-៨-២០០៣ ពីបទប្លន់ចោរកម្មគ្នាច្រើននាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ "គ" ចុះថ្ងៃទី ០៦-០២-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

១០. ទណ្ឌិតឈ្មោះ **មាន សំណាង** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១១-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "គ" ចុះថ្ងៃទី ២៥-០២-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

១១. ទណ្ឌិតឈ្មោះ **តាំង សុគន្ធា** ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-១០-២០០៤ ពីបទប្លន់ ចោរកម្មមានគ្នាច្រើននាក់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ១០ "គ" ចុះថ្ងៃទី ១៨-០២-២០០៥ របស់តុលាការខេត្តបាត់ដំបង ។

១២. ទណ្ឌិតឈ្មោះ **ជា ម៉ុនលីម ហៅ ស្វិត** ភេទ ប្រុស អាយុ ៣៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១១-២០០៣ ពីបទសមគំនិតក្នុងអំពើប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "គ" ចុះថ្ងៃទី ២៥-០២-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

ROYAUME du CAMBODGE * LE MINISTRE du PALAIS ROYAL *

១៣~ ទណ្ឌិតឈ្មោះ **អ៊ី ថុល** ហៅ **ឆា** ភេទប្រុស អាយុ ៤០ ឆ្នាំត្រូវឃុំខ្លួននៅថ្ងៃទី ០៣-១២-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "ត" ចុះថ្ងៃទី ២៥-០២-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

១៤~ ទណ្ឌិតឈ្មោះ **ឆួន សាស់** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៤-៩-២០០៤ ពីបទបង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៦ "ច" ចុះថ្ងៃទី ០៧-០២-២០០៥ របស់តុលាការខេត្តបាត់ដំបង ។

១៥~ ទណ្ឌិតឈ្មោះ **ភា ធឿន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៩-២០០១ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណាចសាលក្រមលេខ ២២ "យ" ចុះថ្ងៃទី ១៤-៣-២០០២ របស់តុលាការខេត្តបាត់ដំបង ។

១៦~ ទណ្ឌិតឈ្មោះ **សំ ម៉ុន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១១-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៦ "ក" ចុះថ្ងៃទី ២៣-៤-២០០៤ របស់តុលាការខេត្តបាត់ដំបង ។

១៧~ ទណ្ឌិតឈ្មោះ **គាង ផេង** ហៅ **នី** ហៅ **កែប សុវណ្ណបញ្ញាសក្តិ** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-០២-២០០៣ ពីបទភេរវកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤៧ ចុះថ្ងៃទី ០៦-១០-២០០៤ របស់តុលាការកំពូល ។

១៨~ ទណ្ឌិតឈ្មោះ **ឆន ឃីត** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-១២-២០០២ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ០៥-០២-២០០៣ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

១៩~ ទណ្ឌិតឈ្មោះ **រ៉ុំ ចន្ថា** ភេទ ប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៥-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណាច សាលក្រមលេខ ១៨៣ ចុះថ្ងៃទី ២៨-១១-២០០១ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២០~ ទណ្ឌិតឈ្មោះ **ឌុយ សុផល** ហៅ **យួន ផល** ភេទ ប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៧-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩២ ចុះថ្ងៃទី ០៧-១២-២០០១ របស់តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ ។

២១. ទណ្ឌិតឈ្មោះ **សារ៉ាយ ឡៀន** ភេទ ប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-៧-២០០១ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩២ ចុះថ្ងៃទី ០៧-១២-២០០១ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២២. ទណ្ឌិតឈ្មោះ **លិត ជួក** ភេទ ប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៩-២០០០ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៨ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី ១៨-០១-២០០១ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២៣. ទណ្ឌិតឈ្មោះ **ឌុច គ្រឹម** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-១១-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី០៨-០១-២០០២ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

មាត្រា ៤ : ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ៦ នាក់ ដែលបានខិតខំ កែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១. ទណ្ឌិតឈ្មោះ **សុខ នូស៊ីន** ភេទប្រុស អាយុ ៥៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១២-២០០២ ពីបទសមគំនិតក្នុងអំពើភេរវកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រមលេខ ៦៨ ចុះថ្ងៃទី ១១-៦-២០០៣ របស់តុលាការខេត្តសៀមរាប ឧត្តរមានជ័យ ។

២. ទណ្ឌិតឈ្មោះ **គួខ ផុន** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-០១-២០០៤ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាល ក្រមលេខ ១៨ ចុះថ្ងៃទី ០៥-៧-២០០៤ របស់តុលាការខេត្តស្ទឹងត្រែង ។

៣. ទណ្ឌិតឈ្មោះ **ដាន់ មុន្នី** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៦-២០០៣ ពីបទរំលោភលើសេចក្តីទុកចិត្ត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣២ ចុះថ្ងៃទី ១២-៩-២០០៣ របស់តុលាការខេត្តរតនគិរី ។

៤. ទណ្ឌិតឈ្មោះ **ម៉ក់ សុខន** ភេទប្រុស អាយុ ៤៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១១-២០០៤ពីបទរំលោភលើសេចក្តីទុកចិត្ត ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាម អំណាចសាលក្រមលេខ ៣៩ "ង" ចុះថ្ងៃទី ០២-៣-២០០៥ របស់តុលាការក្រុងភ្នំពេញ ។

៥. ទណ្ឌិតឈ្មោះ **អែម យ៉េកណា** ភេទស្រី អាយុ ៣៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២២-៣-២០០៦ ពីបទជួញដូរគ្រឿងញៀន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ ៨ ខែ តែអនុវត្តទោសគុក ១ ឆ្នាំ ៨ ខែ និងទោស ២ ឆ្នាំទៀតត្រូវព្យួរចិរវេលាសាកល្បង ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៨ "ឃ" ចុះថ្ងៃទី ០៣-៨-២០០៦ របស់តុលាការខេត្តកំពង់ចាម ។

៦_ ទណ្ឌិតឈ្មោះ ញុំ ឥុខ ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៥-២០០០ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាច សាលក្រមលេខ ១៩៤ "ក" ចុះថ្ងៃទី ២៧-១១-២០០០ របស់តុលាការខេត្តកំពង់ចាម ។

មាត្រា ៤ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរ.ករ.០៧០៥.១៩៥

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ,ថ្ងៃទី *២៧* ខែ*ឧសភា* ឆ្នាំ២០០៧

លេខ: *២០៩* ច.ល

ជម្រាបជូនចែក

រាជធានីភ្នំពេញ,ថ្ងៃទី *២៨* ខែ*ឧសភា* ឆ្នាំ២០០៧

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

-លេខៈ ០៣៩ រស

សេចក្តីសម្រេច

ស្តីពី

របបប្រាក់សោធននិវត្តន៍ នៃតំណាងរាស្ត្រ

ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា

-បានឃើញលទ្ធផល នៃការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំ រដ្ឋសភានាសម័យប្រជុំលើកទី៤ នីតិកាលទី ៣ នៃរដ្ឋសភា កាលពីថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦

-បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៦/០២៩ ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ

-បានឃើញការឯកភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នាសម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កាលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ២០០៧

សម្រេច

ជំពូកទី១

ប្រាក់សោធននិវត្តន៍

ប្រការ១ : តំណាងរាស្ត្រទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌដូចខាងក្រោម :

-ជាតំណាងរាស្ត្រ គិតចាប់ពីឆ្នាំ១៩៩៣ មក

-មានអាយុចាប់ពី៦០ឆ្នាំឡើង

-មិនបានទទួលប្រាក់សោធននិវត្តន៍ពីស្ថាប័នណាមួយរបស់រដ្ឋទេ ។

ប្រការ២ : ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនម្នាក់ៗត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំចុងក្រោយរបស់តំណាងរាស្ត្រម្នាក់ៗ ដោយគិតទាំងឋានៈមុខងារផងដែរ កំណត់ស្មើមួយរយភាគរយ ។

ប្រការ៣ : ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារដូចតទៅ :

-ពី ១ឆ្នាំ ដល់ ៣ឆ្នាំ ទទួលបានសន្ទស្សន៍ 0.៥ %

-លើសពី ៣ឆ្នាំ ដល់ក្រោម ៦ឆ្នាំ ទទួលបានសន្ទស្សន៍ ១ %

-ពី ៦ឆ្នាំ ដល់ក្រោម ១១ឆ្នាំ ទទួលបានសន្ទស្សន៍ ២ %

-ពី ១១ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ ទទួលបានសន្ទស្សន៍ ៣ %

-ពី ១៦ឆ្នាំ ឡើងទៅ ទទួលបានសន្ទស្សន៍ ៤ %

-ចំពោះតំណាងរាស្ត្រក្នុងតំណែងបីអាណត្តិបន្តបន្ទាប់គ្នា ទទួលបានសន្ទស្សន៍ ៤ %

ការគណនាប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជនត្រូវអនុវត្តតាមរូបមន្តដូចខាងក្រោម :

ប្រាក់សោធននិវត្តន៍ប្រចាំខែ = ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃឆ្នាំចុងក្រោយ X សន្ទស្សន៍

ប្រាក់សោធននិវត្តន៍ប្រចាំខែអាចប្រែប្រួលបានទៅតាមប្រាក់បំណាច់និងប្រាក់ឧបត្ថម្ភគ្រប់យ៉ាងនៃថវិកាប្រចាំឆ្នាំចុងក្រោយ ដោយមិនគិតជានិវត្តជនមុន ឬ និវត្តជនក្រោយឡើយ ។

ប្រការ៤ : និវត្តជននៅពេលជាប់ឆ្នោតជាថ្មីជាតំណាងរាស្ត្រ ប្រាក់សោធននិវត្ត មិនត្រូវបានបើកផ្តល់ទៀតទេ ។ សាមីជនត្រូវបើកប្រាក់បំណាច់ជាតំណាងរាស្ត្រជាធម្មតា ហើយនៅពេលចប់អាណត្តិទើបសាមីជនបើកប្រាក់សោធននិវត្តវិញសាជាថ្មី ។

ប្រការ៥ : របៀបគិតអតីតភាពការងារ របស់តំណាងរាស្ត្រ គឺមានដូចតទៅ :

-មានអតីតភាព ចាប់ពី១៦ថ្ងៃឡើងទៅ ត្រូវគិតស្មើ១ខែ ។

-មានអតីតភាព ចាប់ពី៦ខែឡើងទៅ ត្រូវគិតស្មើ១ឆ្នាំ ។

ជំពូកទី២
ភារកិច្ច និងសមត្ថកិច្ចគ្រប់គ្រងប្រាក់សោធននិវត្តន៍

ប្រការ៦ : ជារៀងរាល់ឆ្នាំ អគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវលើកគំរោងផែនការស្ថិតិ និងថវិកាប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមសំរាប់តំណាងរាស្ត្រ ដែលគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍និងទទួលមរណភាព ដោយអនុលោមតាមប្រការ ៣១ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា។

ប្រការ៧ : ការបើកប្រាក់សោធននិវត្តន៍ និងប្រាក់ធានារ៉ាប់រងសង្គមជាសមត្ថកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ។ ៕

ជំពូកទី៣

អវសានប្បញ្ញត្តិ

ប្រការ៨ : គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃរដ្ឋសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភា ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ.ថ្ងៃទី.២១.ខែ.មីនា.ឆ្នាំ២០០៧

ប្រធានរដ្ឋសភា

ហេង សំរិន

<u>ចម្លងជូន</u> :

-ខុទ្ទកាល័យសម្តេចប្រធានរដ្ឋសភា

-ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ រដ្ឋសភា

-ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ រដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដកិច្ច និងហិរញ្ញវត្ថុ

-សមាជិក សមាជិកា រដ្ឋសភា

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

- កាលប្បវត្តិ-ឯកសារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៥៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ. បក ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីអំពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅកំណត់ក្របខណ្ឌ និងលក្ខខណ្ឌចាំបាច់ក្នុងការផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ជាភាសាអង់គ្លេសសរសេរថា Cambodian Specified Rubber ហៅកាត់ថា CSR ។

មាត្រា ២.-

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ៖

- បង្កើនគុណភាពនៃការកែច្នៃកៅស៊ូកម្ពុជា
- ផ្តល់ជំនឿទុកចិត្តដល់អតិថិជនជាតិ និងអន្តរជាតិក្នុងពាណិជ្ជកម្មកៅស៊ូ
- លើកស្ទួយគុណភាពកៅស៊ូកម្ពុជានៅលើទីផ្សារអន្តរជាតិ
- ការពារសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា
- សម្របសម្រួលការធ្វើអាជីវកម្ម ការកែច្នៃ ការនាំចេញ និងការធ្វើឯកភាវូបនីយកម្មយថាប្រភេទកៅស៊ូកម្ពុជា
- ការពារតម្លៃ និងបង្កើនភាពប្រកួតប្រជែងនៃកៅស៊ូកម្ពុជា និង
- បង្កើនចំណូលរដ្ឋលើពន្ធនាំចេញ ឬពន្ធផ្សេងទៀតពាក់ព័ន្ធនឹងបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ។

មាត្រា ៣.-

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចតទៅ ៖

- "កៅស៊ូកែច្នៃ" សំដៅដល់កៅស៊ូស្ងួតដែលកែច្នៃចេញពីទឹកជ័រ និង ជ័រកក
- "យថាប្រភេទកៅស៊ូកម្ពុជា" សំដៅដល់ថ្នាក់គុណភាពនៃកៅស៊ូកែច្នៃដែលត្រូវបានបំប្លែងក្នុងទម្រង់ជាដុំតាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ដូចបានកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- "កៅស៊ូក្រៅយថាប្រភេទ" សំដៅដល់កៅស៊ូកែច្នៃទម្រង់ជាដុំដែលពុំឋិតក្នុងថ្នាក់គុណភាព នៃបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា
- "អ្នកកែច្នៃកៅស៊ូ" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលផលិតកៅស៊ូកែច្នៃ
- "រោងចក្រកែច្នៃកៅស៊ូ" សំដៅដល់កន្លែងផលិតកៅស៊ូកែច្នៃក្នុងទម្រង់ជាដុំ តាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា

-"អ្នកនាំចេញកៅស៊ូ" សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំកៅស៊ូកែច្នៃចេញពីព្រះរាជាណាចក្រកម្ពុជា ដោយប្រើស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា

-"វិញ្ញាបនបត្រ" សំដៅដល់វិញ្ញាបនបត្របញ្ជាក់គុណភាពយថាប្រភេទកៅស៊ូកម្ពុជាដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬដោយមន្ទីរពិសោធន៍មូលដ្ឋានដែលបានទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-"មន្ទីរពិសោធន៍មូលដ្ឋាន" សំដៅដល់មន្ទីរពិសោធន៍យថាប្រភេទ ក្រៅពីមន្ទីរពិសោធន៍ជាតិយថាប្រភេទរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងដែលទទួលស្គាល់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-"របាយការណ៍តេស្ត" សំដៅដល់របាយការណ៍ស្តីពីលទ្ធផលនៃការធ្វើតេស្តសម្រាប់ថ្នាក់កៅស៊ូដែលចេញដោយ វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬមន្ទីរពិសោធន៍មូលដ្ឋានដែលបានទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

ជំពូកទី ២
សមត្ថកិច្ចចេញវិញ្ញាបនបត្រ

មាត្រា ៤.-

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ÷

-ចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូតាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា

-ចេញលិខិតទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋាន

-ចុះបញ្ជិការោងចក្រកែច្នៃកៅស៊ូដែលស្នើសុំវិញ្ញាបនបត្រ និង មន្ទីរពិសោធន៍ដែលស្នើសុំលិខិតទទួលស្គាល់ជាផ្លូវការ

-ចេញវិញ្ញាបនបត្រតាមសំណើរបស់អតិថិជន

-ចេញលិខិតអនុញ្ញាតឱ្យប្រើប្រាស់ ស្លាកសញ្ញាយថាប្រភេទ កៅស៊ូកម្ពុជា

-ចេញសេចក្តីណែនាំបច្ចេកទេសចាំបាច់សម្រាប់ពង្រឹងគុណភាពកៅស៊ូ និងប្រសិទ្ធភាពនៃការកែច្នៃកៅស៊ូដល់អតិថិជន

-កំណត់បទដ្ឋានកៅស៊ូកែច្នៃ តាមបទដ្ឋានអន្តរជាតិនៃទីផ្សារកៅស៊ូ

-ធ្វើការត្រួតពិនិត្យ និង ណែនាំដល់រោងចក្រកែច្នៃកៅស៊ូដែលស្នើសុំវិញ្ញាបនបត្រ

-ធ្វើការត្រួតពិនិត្យ និង ណែនាំដល់មន្ទីរពិសោធន៍មូលដ្ឋាន ដែលស្នើសុំការទទួលស្គាល់ជាផ្លូវការ

-ផ្តល់ឱ្យ ព្យួរ ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការ ឬ វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ

-ព្យួរ ឬ លុបចោលបញ្ជិការោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍មូលដ្ឋាន និង

-ទំនាក់ទំនង ឬ រាយការណ៍ជូនស្ថាប័នអាណាព្យាបាល ឬ ភ្នាក់ងារពាក់ព័ន្ធអំពីវិញ្ញាបនកម្មយថាប្រភេទកៅស៊ូកម្ពុជា ។

បែបបទ និង នីតិវិធីសម្រាប់ការសុំ និងការផ្តល់វិញ្ញាបនបត្រ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៥.-

មន្ទីរពិសោធន៍មូលដ្ឋានមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម ÷

-ចេញវិញ្ញាបនបត្រជាផ្លូវការស្របតាមអនុក្រឹត្យនេះ

-ស្នើសុំចុះបញ្ជិកានៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីទទួលបានសិទ្ធិចេញវិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ និង លិខិតទទួលស្គាល់ជាផ្លូវការ

-ស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-ធ្វើការវិភាគដោយផ្ទាល់ ឬ ធ្វើសេវាកម្មវិភាគគុណភាពកៅស៊ូ តាមយថាប្រភេទកៅស៊ូកម្ពុជា ក្រោយពេលបានចុះបញ្ជិការួច និង ទទួលលិខិតទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

-គោរពតាម ទទួលយក ឬ កែតម្រូវតាមលក្ខខណ្ឌ និង ការណែនាំរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា លើផ្នែកបច្ចេកទេសមន្ទីរពិសោធន៍ និង ការវិភាគគុណភាពកៅស៊ូ

-ប្រើប្រាស់ស្លាកសញ្ញារបស់ខ្លួនផ្ទាល់ បន្ថែមលើស្លាកសញ្ញាគុណភាពយថាប្រភេទកៅស៊ូកម្ពុជារបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

មាត្រា ៦.-

គំរូបញ្ជិកា វិញ្ញាបនបត្រ លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង លិខិតទទួលស្គាល់ជាផ្លូវការ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ៧.-

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលនាំចេញកៅស៊ូកែច្នៃជាទម្រង់ដុំ ត្រូវមានវិញ្ញាបនបត្រតាមបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា ដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន លើកលែងតែកៅស៊ូដែលនាំចេញមានបរិមាណតិចជាង ៥ (ប្រាំ) គីឡូក្រាម សម្រាប់ធ្វើជាសំណាក ។

អ្នកនាំចេញយថាប្រភេទកៅស៊ូកម្ពុជា ត្រូវបង្ហាញវិញ្ញាបនបត្រចំពោះអាជ្ញាធរមានសមត្ថកិច្ចដើម្បីត្រួតពិនិត្យ ជាផ្នែកមួយក្នុងសំណុំបែបបទនាំចេញ ។

អ្នកនាំចេញកៅស៊ូក្រៅយថាប្រភេទកៅស៊ូកម្ពុជា ត្រូវបង្ហាញរបាយការណ៍តេស្តដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬ មន្ទីរពិសោធន៍មូលដ្ឋាន ។

មាត្រា ៨.-

អ្នកកែច្នៃកៅស៊ូដែលមានបំណងបញ្ជាក់គុណភាពកៅស៊ូ ត្រូវដាក់ពាក្យស្នើសុំនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ។

មន្ទីរពិសោធន៍ត្រូវធ្វើតេស្តបច្ចេកទេសសំណាកកៅស៊ូពីអតិថិជន ដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ ស្របតាមវិធីវិភាគដែលបានទទួលស្គាល់ មុនពេលចេញវិញ្ញាបនបត្រ ។

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬមន្ទីរពិសោធន៍មូលដ្ឋាន ត្រូវចេញវិញ្ញាបនបត្រចំនួន ៥ (ប្រាំ) ច្បាប់ដើម ដែលមានហត្ថលេខានាយកនិងត្រារបស់វិទ្យាស្ថាន ស្រាវជ្រាវកៅស៊ូកម្ពុជា ឬនាយកមន្ទីរពិសោធន៍មូលដ្ឋាន ។

ក្នុងករណីដែលលទ្ធផលនៃការធ្វើតេស្តបង្ហាញថា គុណភាពកៅស៊ូមិនចូលក្នុងថ្នាក់ណាមួយនៃបទដ្ឋានយថាប្រភេទកៅស៊ូកម្ពុជា មន្ទីរពិសោធន៍ត្រូវជូនដំណឹងនេះទៅអ្នកស្នើសុំ ហើយត្រូវបញ្ជាក់ក្នុងរបាយការណ៍តេស្តជាកៅស៊ូក្រៅថ្នាក់ ។

ជំពូកទី ៣
ការទទួលស្គាល់មន្ទីរពិសោធន៍មូលដ្ឋានជាផ្លូវការ និង ការត្រួតពិនិត្យរោងចក្រកែច្នៃកៅស៊ូ

មាត្រា ៩.-

រាល់មន្ទីរពិសោធន៍យថាប្រភេទកៅស៊ូកម្ពុជា ត្រូវស្នើសុំការទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ពីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដើម្បីទទួលបានសិទ្ធិចេញវិញ្ញាបនបត្រ និង សិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ។

លិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតឱ្យប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ត្រូវផ្តល់ឱ្យសម្រាប់រយៈពេល ៣ (បី) ឆ្នាំ លើកលែងតែក្នុងករណីមានការដកហូតវិញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ដោយសារមូលហេតុដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ ។

បែបបទ និងនីតិវិធីនៃការផ្តល់លិខិតទទួលស្គាល់ជាផ្លូវការ និង លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ១០.-

វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា មានសិទ្ធិធ្វើតេស្តបច្ចេកទេស ធ្វើការត្រួតពិនិត្យ និង វាយតម្លៃលើប្រតិបត្តិការរបស់រោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍មូលដ្ឋាន ដើម្បីធានាឱ្យបាននូវអនុលោមភាពរបស់រោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍ទាំងនោះទៅនឹងលក្ខខណ្ឌចាំបាច់ក្នុងការផ្តល់វិញ្ញាបនបត្រ

ជំពូកទី ៤
ការបង់កម្រៃ

មាត្រា ១១.-

រោងចក្រកែច្នៃកៅស៊ូ និង មន្ទីរពិសោធន៍មូលដ្ឋានដែលស្នើសុំចុះបញ្ជិកា ស្នើសុំលិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង ស្នើសុំលិខិតទទួលស្គាល់ជាផ្លូវការនៅវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវបង់កម្រៃសេវាកម្មសម្រាប់ចុះបញ្ជិកា កម្រៃលើសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និងកម្រៃទទួលស្គាល់ជាផ្លូវការ ។

អ្នកស្នើសុំវិញ្ញាបនបត្រ ត្រូវបង់កម្រៃសេវាកម្មសម្រាប់ការធ្វើតេស្ត និង ការចេញវិញ្ញាបនបត្រ ។

កម្រៃសេវាកម្មសម្រាប់ចុះបញ្ជិកា កម្រៃសេវាកម្មសម្រាប់ការធ្វើតេស្តនិងការចេញវិញ្ញាបនបត្រ កម្រៃលើសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង កម្រៃទទួលស្គាល់ជាផ្លូវការ ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ជំពូកទី ៥
ការព្យួរ ការដកហូតលិខិតទទួលស្គាល់ជាផ្លូវការ និង ការពិន័យ

មាត្រា ១២.-

ក្នុងករណីរោងចក្រកែច្នៃកៅស៊ូ ឬ មន្ទីរពិសោធន៍មូលដ្ឋានដែលត្រូវបានទទួលស្គាល់ជាផ្លូវការ និង ទទួលសិទ្ធិប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា បានប្រព្រឹត្តកំហុសធ្ងន់ធ្ងរក្នុងលក្ខណៈបច្ចេកទេស វិទ្យាស្ថានមានសិទ្ធិសម្រេចព្យួរ ឬ ដកហូតលិខិតទទួលស្គាល់ជាផ្លូវការ លិខិតអនុញ្ញាតប្រើប្រាស់ស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា និង បញ្ជិការោងចក្រកែច្នៃកៅស៊ូ ឬ មន្ទីរពិសោធន៍មូលដ្ឋាន ។

មាត្រា ១៣.-

បុគ្គលទាំងឡាយណាដែលនាំចេញកៅស៊ូក្នុងទម្រង់ជាដុំ ដោយគ្មានវិញ្ញាបនបត្រ ឬ របាយការណ៍តេស្តចំពោះកៅស៊ូក្រោយថាប្រភេទកៅស៊ូកម្ពុជា ដែលចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬដោយមន្ទីរពិសោធន៍មូលដ្ឋាន ត្រូវផ្តន្ទាទោសស្របតាមមាត្រា ៦២ នៃច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ។

មាត្រា ១៤.-

ត្រូវផ្តន្ទាទោសស្របតាមមាត្រា ៦៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា ចំពោះ :

១-បុគ្គលទាំងឡាយណាដែលនាំចេញកៅស៊ូដោយប្រើស្លាកសញ្ញាយថាប្រភេទកៅស៊ូកម្ពុជា ដោយគ្មានវិញ្ញាបនបត្រចេញដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ឬដោយមន្ទីរពិសោធន៍មូលដ្ឋាន ។

២-បុគ្គលទាំងឡាយណាដែលនាំចេញកៅស៊ូ ដោយក្លែងគុណភាពយថាប្រភេទកៅស៊ូកម្ពុជាខុសពីវិញ្ញាបនបត្រ ។

មាត្រា ១៥.-

អ្នកឯកទេសក្នុងក្របខ័ណ្ឌនៃមន្ទីរពិសោធន៍មូលដ្ឋាន ឬមន្ទីរពិសោធន៍នៃវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរបាយការណ៍តេស្តរបស់ខ្លួន ។ ក្នុងករណីមានការឃុបឃិតក្លែងគុណភាពយថាប្រភេទកៅស៊ូកម្ពុជា ត្រូវផ្តន្ទាទោសស្របតាមមាត្រា ៧០ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាពសុវត្ថិភាព លើផលិតផលទំនិញ និងសេវា ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងៗទៀត ។

ជំពូកទី ៦
អវសានប្បញ្ញត្តិ

មាត្រា ១៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៧.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការសំរួល និង ប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និង ថ្នាក់ របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ំ រេ ច

មាត្រា ១ : ត្រូវបានសំរួលភារកិច្ចលោក **សៅ សារឹម** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៦ ពីអភិបាលស្រុកអូររាំង ខេត្តមណ្ឌលគិរី ឱ្យមកបំរើការងារនៅសាលាខេត្តមណ្ឌលគិរី ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល ។

មាត្រា ២ : ប្រគល់ភារកិច្ចជូនលោក **នួន សារិន** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៥ ជាអភិបាលស្រុកអូររាំង ខេត្តមណ្ឌលគិរី ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល ។

មាត្រា ៣ : លោក **នួន សារ៉ែន** ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២១០/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និង ប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីជន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៥ (ដើម្បីអនុវត្ត)*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៤៩០ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការកែតម្រូវមាត្រា១ នៃអនុក្រឹត្យលេខ ៣១៥ អនក្រ.តត
ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៦ ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានកែតម្រូវមាត្រា ១ នៃអនុក្រឹត្យលេខ ៣១៥ អនក្រ.តត ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៦ ស្តីពីការប្រគល់ភារកិច្ចជូនលោក **មាស យុន្ន** ជាអភិបាលរងខេត្តកណ្តាល ពីឋានន្តរសក្តិ ឧត្តមសេនីយ៍ត្រី នៃក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ មកជាឋានន្តរសក្តិ ឧត្តមសេនីយ៍ទោ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៤១ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការផ្លាស់ប្តូរ និង ប្រគល់ភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានផ្លាស់ប្តូរភារកិច្ចលោក ញឹក គីមឈុន ឋាន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាលរងខេត្តបាត់ដំបង អោយទៅទទួលភារកិច្ចថ្មី ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនលោក គឹម ឈាន ឋាន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៦ ជាអភិបាលរងខេត្តបាត់ដំបង ។

មាត្រា ៣ : លោក គឹម ឈាន ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៥ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២២ . អនក្រ . តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **អៀង សុវណ្ណនារ៉ា** ជាអគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងបរិស្ថាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២៣.អនក្រ-បក

អនុក្រឹត្យ

ស្តីពីការតម្លើងថ្នាក់

មន្ត្រីរាជការក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្នុងឋានន្តរស័ក្តិវរមន្ត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤/០៩ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

ស ម្រេ ច

មាត្រា ១.-

ត្រូវបានតម្លើងថ្នាក់លោក **សែ សាមុត** ពីឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ ៨ ទៅថ្នាក់លេខ ៧ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ គិតចាប់ពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៧ ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *" រាជកិច្ច "*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពិសោធន៍សំណង់ និងសាធារណការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតមន្ទីរពិសោធន៍សំណង់ និងសាធារណការ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

ស ម្រេ ច

មាត្រា ១.-

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពិសោធន៍សំណង់ និងសាធារណការ ដូចមានរាយនាម ខាងក្រោម :

១- ឯកឧត្តម	**ពូច ចាន់កុសល**	តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន	ជាប្រធាន
២- ឯកឧត្តម	**គង់ អួក**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
៣- លោក	**ឃុន ហ្សុលីន**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
៤- លោក	**គីម ទូច**	តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	ជាសមាជិក
៥- លោក	**ជា ស៊ីថា**	តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ជាសមាជិក
៦- លោក	**កែវ លាប**	អគ្គនាយកមន្ទីរពិសោធន៍សំណង់ និងសាធារណការ	ជាសមាជិក
៧- លោក	**ពេជ្រ វុឌ្ឍី**	តំណាងនិយោជិតមន្ទីរពិសោធន៍សំណង់ និងសាធារណការ	ជាសមាជិក

មាត្រា ២.-

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសា-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោកវរសេនីយ៍ឯក **មាស ចំនួសុផល** ជាជំនួយការឯកឧត្តមអនុប្រធានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើប្រធាននាយកដ្ឋាន ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

